# មជ្ឈមណ្ឌលឯកសារកម្ពុជា

PTI0059

សម្ភាសន៍ជាមួយឈ្មោះ ឡេង ភាព ភេទប្រុស អាយុ៥៧ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានអនុសេនាតូច កងពលលេខ៨០១

ស្រុកកំណើតនៅភូមិចក ឃុំកំពង់ចិន ស្រុកស្ទោង ខេត្តកំពង់ធំ

សព្វថ្ងៃរស់នៅភូមិស្ទឹងថ្មី ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០១:០៩:៥៨

៣៨ទំព័រ

ដានី ៈ ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូៗឈ្មោះពេញ ឈ្មោះអី?

ភាព ៈ បាទ! ខ្ញុំឈ្មោះ ឡេង ភាព។

ដានី ៈ អាយុប៉ុន្មានហើយលោកពូ?

ភាព ៈ ឥឡូវអាយុ៥៧។

ដានី ៈ ចុះមីងគាត់ឈ្មោះអីដែរ?

ភាព ៈ ព្រំ ណៃ។

ដានី ៈ មីងអាយុប៉ុន្មានហើយ?

ភាព ៈ ៥១។

ដានី ៈ ចុះពូសព្វថ្ងៃរស់នៅក្នុងភូមិ ឃុំ ស្រុកអីដែរ?

ភាព ៈ បាទ! ភូមិស្ទឹងថ្មី ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។

ដានី ៈ ពូសព្វថ្ងៃប្រកបមុខរបររកស៊ីធ្វើអីដែរ?

ភាព ៈ បាទ! ធ្វើចំការ។

ដានី ៈ ធ្វើតែចំការទេ?

ភាព ៈ បាទ! ធ្វើចំការ។

ដានី ៈ អត់មានធ្វើស្រែធ្វើអីទេ?

ភាព ៈ ស្រែស្រុកយើងនេះ អត់មាន ធ្វើចំការ ស្រូវក៏ដាំ ពោត សណ្តែក។

ដានី ៈ ពូមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

ភាព ៈ សព្វថ្ងៃនៅ៦នាក់។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ភាព ៖ ប្រុស៥ ស្រី១ ក្រៅពីនឹងគេមានប្ដីបែកអស់ហើយ សល់៦នាក់ ។

ដានី ៖ ក្រៅពីនឹងមានប្ដីបែកអស់ហើយ?

ភាព ៖ បាទ!

ដានី ៖ មានប្ដីបានប៉ុន្មាននាក់?

ភាព ៖ បាន២ ។

ដានី ៖ បាន២នាក់ ទាំងអស់៨នាក់?

ភាព ៖ បាទ!

ដានី ៖ ៨នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ភាព ៖ ស្រី៣ ប្រុស៥ ។

ដានី ៖ ចុះពូស្រុកកំណើតពូ?

ភាព ៖ ខ្ញុំនៅកំពង់ធំ ។

ដានី ៖ ភូមិអីគេទៅ?

ភាព ៖ ភូមិចក ។

ដានី ៖ ភូមិចក?

ភាព ៖ បាទ! ឃុំកំពង់ចិន ។

ដានី ៖ ឃុំកំពង់ចិន?

ភាព ៖ បាទ! ស្រុកស្ទោង ខេត្តកំពង់ធំ ។

ដានី ៖ កំពង់ចិន ជាមួយខុចដែរ?

ភាព ៖ បាទ!

ដានី ៖ ខុសតែភូមិទេចឹង?

ភាព ៖ ខុសភូមិ ។

ដានី ៖ ចុះពូស្គាល់គ្រួសារគាត់ច្បាស់ដែរ?

ភាព ៖ អត់ទេ អត់បានស្គាល់ ។

ដានី ៖ ឪពុកពូ គាត់ឈ្មោះអីទៅ?

ភាព ៖ ពិល ឡេង ។

ដានី ៖ ពិល ឡេង សព្វថ្ងៃគាត់នៅរស់ ហើយ?

ភាព ៖ ស្លាប់អស់ហើយ ។

ដានី ៖ គាត់ស្លាប់ឆ្នាំណាទៅ?

ភាព ៖ អត់ដឹងដែរ ព្រោះអ៊ីខ្ញុំមកយូរហើយ ទើបមកផ្ទះបានម្តង តាំងពី៧០ តាំងពីអាយុ១៨ ។

ដានី ៖ ចុះម្តាយ?

ភាព ៖ ម្តាយ ស៊ុន យ៉ែម ។

ដានី ៖ ស៊ុន យ៉ែម គាត់នៅរស់ ឬក៏ស្លាប់?

ភាព ៖ ស្លាប់ដូចគ្នា ។

ដានី ៖ អត់ដឹងគាត់ស្លាប់ពីឆ្នាំណា?

ភាព ៖ ឆ្នាំណាទេ ដូចភ្លេចបាត់ហើយនឹង ប្រាប់ ឪពុកក៏ប្រាប់ មិនដឹងជាឆ្នាំ ។

ដានី ៖ ចុះពូមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់?

ភាព ៖ សព្វថ្ងៃសល់៣នាក់ ។

ដានី ៖ បាទ! ទាំងអស់ម៉ង?

ភាព ៖ បាទ!

ដានី ៖ បងប្អូនទាំងអស់ប៉ុន្មាននាក់?

ភាព ៖ ទាំងអស់៥នាក់ ស្លាប់២ ។

ដានី ៖ ៥នាក់ ស្លាប់អស់២?

ភាព ៖ ហ៎! សល់៣នាក់ ។

ដានី ៖ ស្លាប់អស់៣ ចឹងនៅសល់តែ២នាក់ទេ?

ភាព ៖ សល់ៗ៣ ស្លាប់៣ ។

ដានី ៖ សល់៣ ស្លាប់៣?

ភាព ៖ ហ្នឹង មិនមែន៥ ៦ ។

ដានី ៖ ៦នាក់ ស្លាប់៣នៅសល់៣?

ភាព ៖ បាទ!

ដានី ៖ ៦នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ភាព ៖ ស្រីតែ១ ។

ដានី ៖ ស្រីម្នាក់ ប្រុស៥?

ភាព ៖ បាទ!

ដានី ៖ ចឹងស្លាប់៣នាក់ គាត់ស្លាប់ដោយសារអីទៅ?

ភាព ៖ ស្លាប់ឈឺទេ អត់មានដោយសារអត់បាយ អត់អីទេ គឺជម្ងឺ ។

ដានី ៖ ចឹងលោកពូកូនទីប៉ុន្មាន?

ភាព ៖ ខ្ញុំៗកូនទី៣ ។

ដានី ៖ ចឹងកាលពីក្មេងៗ ពូបានរៀនសូត្រអីដល់ណាដែរ?

ភាព ៖ រៀនថ្នាក់ទី៩ ។

ដានី ៖ ថ្នាក់ទី៩?

ភាព ៖ បាទ!

ដានី ៖ ទី៩ ចាស់ពីដើម?

ភាព ៖ ទី៩ចាស់ ។

ដានី ៖ ទី៩ចាស់នៅសាលាណាដែរ?

ភាព ៖ សាលាបឋមសិក្សាកំពង់ចិន ។

ដានី ៖ សាលាបឋមសិក្សា វត្ត?

ភាព ៖ អត់វត្តទេ កំពង់ចិន ។

ដានី ៖ សាលាបឋមសិក្សាកំពង់ចិន?

ភាព ៖ បាទ!

ដានី ៖ ពូរៀនដល់ឆ្នាំណាទៅបានឈប់?

ភាព ៖ ៦៩ បានឈប់ ។

ដានី ៖ មូលហេតុអីបានឈប់ឆ្នាំ៦៩?

ភាព ៖ ស្រុកកើតកន្ទល់ ។

ដានី ៖ ក្រែងឆ្នាំ៦៩ អត់ទាន់?

ភាព ៖ អត់ទាន់អីទេ ប៉ុន៧០ យើងរដ្ឋប្រហារ ។

ដានី ៖ ចឹងពូឈប់រៀន ហើយពូធ្វើអីទៀតទៅ?

ភាព ៖ ធ្វើស្រែៗបាន នៅជាមួយម៉ែឪមិនបាន២ឆ្នាំ ។ ជា២ឆ្នាំ ។

ដានី ៖ ម៉េចទៀតទៅ?

ភាព ៖ ចូលធ្វើបដិវត្តន៏ឹងមករហូត ។

ដានី ៖ ចឹងពូចូលធ្វើបដិវត្តឆ្នាំណា?

ភាព ៖ តាំងពីឆ្នាំ៧០ ។

ដានី ៖ ឆ្នាំ៧០ម៉ង?

ភាព ៖ ឆ្នាំ៧១ ។

ដានី ៖ ឆ្នាំ៧១ ពូចូលធ្វើបដិវត្តនឹង ពូចូលយ៉ាងម៉េច យើងខបមាថា យើងដូចថា យើងស្ម័គ្រចិត្ត ទៅ ឬក៏កាលនឹងយើងមានការជ្រើសរើសទៅ?

ភាព ៖ អត់ៗមានការចាប់បង្ខំទេអានឹង ដោយសារស្ម័គ្រចិត្ត ស្តាប់ការអំពាវនាវពីតាសីហនុ ឲ្យចូលព្រៃម៉ាគី សិស្សសាលាឈប់រៀន ចូលបណ្តោយ គ្មានបានអីរៀន ។

ដានី ៖ ដល់ពេលចឹងដល់ឆ្នាំ៧១នឹង ពូស្ម័គ្រចិត្តតាមការអំពាវនាវរបស់សម្តេចសីហនុ?

ភាព ៖ បាទ!

ដានី ៖ ចូលដូចថា ពូអាចរៀបរាប់យើងចូលយ៉ាងម៉េច ពីដំបូងចូលទៅនៅណា បន្ទាប់មកទៀត?

ភាព ៖ អានេះយើងមុនដំបូង គេមានអ្នកជ្រើសរើសនៅក្នុងភូមិស្រេច ចូលទៅតាមភូមិៗបានគេបញ្ចូលឲ្យយើងទៅរៀនសូត្រគោលនយោបាយ ។

ដានី ៖ ចឹងពូចូលបដិវត្តដំបូងពូនៅណា?

ភាព ៖ នៅនឹងស្រុកៗស្ទោង ចេញពីស្រុកបានមក គេបញ្ជូនមកធ្វើទ័ព យើងស្ម័គ្រចិត្ត យើងមកធ្វើទ័ពធ្វើ បើយើងអត់ធ្វើយើងសុំគេ នៅខាងមូលដ្ឋាន ខាងស្អី ខាងសេដ្ឋកិច្ច ឬក៏ខាងកសិកម្ម ខស្បៀហ៍កម្មស្រេចតែយើង តាមស្ម័គ្រចិត្ត ។

ដានី ៖ ចឹងពូចូលទៅនៅស្រុកស្ទោង បានរយៈពេលប៉ុន្មានទៅ?

ភាព ៖ មើលរយៈបានប្រហែលជា រកប្រហែលមិនឃើញ មើលពិសាខ ជេស្ឋ អឺ!បានប្រហែល២ ខែមកហាត់យោធា ។

ដានី ៖ ចូលនៅស្ទោងបាន២ខែ?

ភាព ៖ បាទ! ២ខែ បានគេបញ្ជូនមកកំពង់ធំ ហាត់បច្ចេកទេស ដល់ខែ១២ ៧២នោះ បានទៅសៀមរាប ។

ដានី ៖ ហាត់យោធានៅកំពង់ធំ?

ភាព ៖ បាទ!

ដានី ៖ ដល់ពេលខែ១២?

ភាព ៖ ខែ១២ ៧២ បានទៅសៀមរាប ។

ដានី ៖ ៧២ ទៅសៀមរាប ទៅយ៉ាងម៉េច?

ភាព ៖ ទៅទាហាន ទៅទ័ព គឺនៅការពារនៅអង្គរវត្ត ។

ដានី ៖ កងទ័ពការពារអង្គរវត្ត?

ភាព ៖ បាទ! ៧៤ ខែ១ បានខ្ញុំមកភ្នំពេញ អូ!ខែ១ ខែ២ ។

ដានី ៖ ចឹងលោកពូ កាលនឹងពេលលោកពូមកសៀមរាប ពូនៅក្នុងកងអី?

ភាព : កងទ័ព ។

ដានី : កងទ័ពបានន័យថា យើងនៅក្នុងកងដូចថាកងវរៈ កងពលណាដែរ?

ភាព : បាទ! នៅហើយស្រេច នៅក្នុងអង្គភាពកងវរៈសេនាតូច ។

ដានី : កងវរៈសេនាតូច?

ភាព : បាទ! អត់ទាន់មានវរៈសេនាធំទេ ពួកខ្ញុំមានត្រឹមតែវរៈសេនាតូច ។

ដានី : អូ! មានវរៈសេនាតូចនៅឡើយ?

ភាព : បាទ!

ដានី : កងវរៈសេនាតូចនឹង នៅខាងជើងការពារអង្គរ?

ភាព : បាទ! នៅការពារអង្គរ ។

ដានី : កាលនឹងក្រែង ដូចថានៅឆ្នាំ៧២នឹង នៅខាងសៀមរាបនឹង ក្រែងលន់ នល់ គេគ្រប់គ្រង ដែរ?

ភាព : អត់ទេ គ្រប់គ្រងតែនៅផ្សារសៀមរាប តែអង្គរវត្តគឺខ្មែរក្រហមកាន់កាប់ ។

ដានី : អូ! ចឹងខាងអង្គរនឹង ខាងខ្មែរក្រហមអ្នកគ្រប់គ្រង?

ភាព : បាទៗ នៅពេញប៉ឹប ។

ដានី : ខាងទីក្រុងសៀមរាបនេះ តែលន់ នល់?

ភាព : បាទ! តែទីក្រុងទេ លន់ នល់ ។

ដានី : ប៉ុន្តែអ្នកដែលកងទ័ពការពារអង្គរនឹងមានតែម៉ាវរៈសេនាតូចទេ?

ភាព : បាទ! វរសេនាតូច ។ អត់ទេ ពួកវាមានកងតំបន់ កងភាគ កងស្រួច ដោយឡែកតែពួកខ្ញុំ គឺទៅនៅនឹងទៅ ។

ដានី : ចុះពូ កាលនឹងកងអីគេ កងតំបន់?

ភាព : អត់ទេ អត់មានតំបន់ អត់មានស្រុកអីទេ គឺកងស្រួច គេហៅកងទ័ពស្រួច ។

ដានី : កងទ័ពស្រួច ចំនុះឲ្យខាងណា?

ភាព : កងរបស់មជ្ឈឹម ។

ដានី : កងរបស់មជ្ឈឹម?

ភាព : បាទ! អត់មានភាគណា ក៏អត់មានដែរ គឺយើងទូទាំងប្រទេស យើងស្រេចតែខាងលើត្រូវ ការយកទៅខាងណាក៏បាន យកទៅវៃនៅកន្លែងណាក៏បាន ។

ដានី : ម៉ាវរៈសេនាតូចពូ មានគ្នាប៉ុន្មាននាក់?

ភាព : វា៤០០នាក់ជាង ។ វាពេញៗ កាលនឹង ។

ដានី ៖ កាលនឹងប្រធានវរៈសេនាតូច របស់ពូពីណាគេ?

ភាព ៖ ប៉ៃ តាឡឺ អឺ!ធិនទេ។

ដានី ៖ បាទ?

ភាព ៖ ធិនៗ ។

ដានី ៖ ឈ្មោះ ធិន?

ភាព ៖ បាទ! គាត់ស្លាប់បាត់ហើយ ធិនក៏ស្លាប់ តាឡឺក៏ស្លាប់ ជនជាតិ។ មេខ្ញុំសុទ្ធតែជនជាតិទេ។

ដានី ៖ ធិន ឡឺ។ ធិន នឹងគាត់ជនជាតិ?

ភាព ៖ ជនជាតិលាវ ។

ដានី ៖ តាឡឺ?

ភាព ៖ បាទ! នែក! ចារាយ តាឡឺ។

ដានី ៖ តាឡឺ ចារាយ ធិននឹងលាវ?

ភាព ៖ បាទ! ពាវក៏ចារាយ ប៉ៃលាវ ។

ដានី ៖ ហ៊ា ម៉េចចឹង?

ភាព ៖ ៤នាក់ ។

ដានី ៖ ចាំមើលឈ្មោះ ធិន ជនជាតិលាវ?

ភាព ៖ លាវ ។

ដានី ៖ ឈ្មោះ ឡឺ ជនជាតិចារាយ?

ភាព ៖ បាទ!

ដានី ៖ តាប៉ៃ ជនជាតិឡាវ?

ភាព ៖ លាវ ។

ដានី ៖ ហើយមួយទៀត?

ភាព ៖ ៣ គាត់ចារាយ ។

ដានី ៖ ម៉េចចឹង សុទ្ធតែជនជាតិចឹង?

ភាព ៖ អឺ! ចុះខ្លះមានទំពួន មានព្នង។

ដានី ៖ គាត់មកពីខាងណាមក?

ភាព ៖ បាទ! គាត់នៅរតនគីរី ។

ដានី ៖ គាត់នៅរតនគីរី គាត់មកធ្វើប្រធានវរសេនាតូចរបស់ពូ?

ភាព ៖ បាទ! ចុះបើគាត់តស៊ូតាំងពី៦៧ ៦៨ គាត់នៅមួយគាៗតាំងពីបាតជើងក្រហម នៅតាំងពីនិរសា តាំងពីដាំទឹកក្តៅ ។

ដានី ៖ ចុះពូមានតួនាទីអីកាលនឹង?

ភាព ៖ ខ្ញុំកាលនោះ ធ្វើមេក្រុម ។

ដានី ៖ ធ្វើមេក្រុម?

ភាព ៖ បាទ!

ដានី ៖ មេក្រុមមានគ្នាប៉ុន្មាននាក់?

ភាព ៖ ម៉ាក្រុមពួកខ្ញុំវាមាន១២នាក់ៗ ស្មើនឹងស្មើជើង វាត្រូវម៉ាអនុសេនាធំ ព្រោះពួកខ្ញុំអត់ដែលនៅនេះទេ នៅកងពិសេស នៅជាមួយមេៗ ។

ដានី ៖ ចុះលោកពូនៅការពារនៅអង្គរនឹងរយៈពេលប៉ុន្មានទៅ?

ភាព ៖ ៧៤បានខ្ញុំចេញមក ។

ដានី ៖ នៅនឹងរហូតដល់ឆ្នាំ៧៤?

ភាព ៖ បាទ! ៧៤ ខែ៣ មើលខែ៣ខ្ញុំត្រូវរបួស ខែ២ចេញមកទម្រាំដល់ មកយើងភ្នំពេញវាយូរដែរ ដើរ ។

ដានី ៖ ខែ២ចេញពីអង្គរមក?

ភាព ៖ បាទ! ខែរងា ។

ដានី ៖ ចេញពីអង្គរមក?

ភាព ៖ មកភ្នំពេញ មកឧត្តុង្គ ។

ដានី ៖ មកសមរភូមិភ្នំពេញ?

ភាព ៖ បាទ! ហៅសមរភូមិ ភូមិភាគពិសេស វៃទាហានលន់ នល់ ។

ប្រពន្ធ ៖ គាត់នឹងតួនាទីកងពិសេស ។

ដានី ៖ ចឹងពូ ពេលនឹងពូចេញមកនឹង មកមុខព្រួញនៅកន្លែងណា?

ភាព ៖ មកនេះ ម្តុំៗ ។

ដានី ៖ ម្តុំមកខាង?

ភាព ៖ បាទ! ភ្នំអស្តួរស ភ្នំបាសិត គេហៅភូមិភាគពិសេស រហូតដល់គ្នារំដោះ៧៥ បានទៅនៅរតនគិរី ។

ដានី ៖ ឧត្តុង្គនៅភូមិភាគពិសេស?

ភាព ៖ បាទ! ភូមិភាគពិសេស ជុំវិញភ្នំពេញ ពាយ័ព្យភ្នំពេញ សមរភូមិពាយ័ព្យ ។

ដានី ៈ កាលនឹងពេលដែលពូដកមកភ្នំពេញចឹង ពូមាននៅក្នុងកងពលអី អត់?

ភាព ៈ នៅក្នុងកងពល១៨ ។

ដានី ៈ នៅកងពល១១?

ភាព ៈ បាទ! កងពលលេខ១៨ ។

ដានី ៈ កងពលលេខ១៨?

ភាព ៈ បាទ! កងពលក៏ស្លាប់ដែរ ឥឡូវបងសារឿនស្លាប់ សានក៏ស្លាប់ ។

ដានី ៈ ចឹងកាលនឹងនៅកងពលលេខ១៨នឹង តាសារឿន គាត់ប្រធានកងពល១៨?

ភាព ៈ បាទ! គាត់ប្រធានកងពល ។

ដានី ៈ អឺ! តាសាន?

ភាព ៈ គាត់ខាងយោធា ។

ដានី ៈ គាត់បន្ទាប់?

ភាព ៈ មួយនយោបាយ មួយយោធា ។

ដានី ៈ មួយនយោបាយ មួយយោធា?

ភាព ៈ បាទ!

ដានី ៈ តែកងពល១៨នឹង?

ភាព ៈ បាទ! ស្លាប់អស់ ។

ដានី ៈ តាសារឿន មាន២នាក់?

ភាព ៈ បាទ! មួយ ស សារឿន។ សារឿនមួយ កែវ សារឿន ។

ដានី ៈ មួយសារឿន មួយ?

ភាព ៈ កែវ សារឿន ហ្នឹងនឹងគាត់ទើបឡើងកងពលទេ ។ កាលយើងនៅនឹងគាត់វរៈសេនាធំ ដល់យើងឯករាជ្យហើយ បានគាត់ឡើងកងពល ។ ពីមុនមានបងសារឿន ហើយនឹងសាន ។

ដានី ៈ តែបងសារឿនហ្នឹង?

ភាព ៈ ស សារឿន បាទ! នៅតាកែវ កំពត ។

ដានី ៈ ស សារឿន នៅតាកែវ ហើយតាសាន គាត់ឈ្មោះអីសាន?

ភាព ៈ ហ៎! បងសាន ដូចឈ្មោះស៊ីទេ ប៉ុនគាត់នៅដូចស៊ឹងត្រែង ។

ដានី ៈ ស៊ឹងត្រែង ហើយនឹងតាកែវ សារឿន?

ភាព ៈ មិនមានទេ កែវ សារឿនស្លាប់ហើយ ។

ដានី ៈ កែវ សារឿនស្លាប់ហើយ?

ភាព ៖ បាទ! កែវ សារឿន ទើបនឹងឡើង១៧៥ ។

ដានី ៖ កែវ សារឿន ទើបនឹងឡើងនឹង ស្រុកគាត់នៅខាងណា?

ភាព ៖ នៅខាង បែបម្ដុំស្អាង កោះធំ ។ អត់ៗដឹងទេ ។

ដានី ៖ ដល់ពេលពូៗមកនៅកងពលនឹង ពូមានតួនាទីអី?

ភាព ៖ អនុសេនាតូច ។

ដានី ៖ អនុសេនាតូច?

ភាព ៖ បាទ!

ដានី ៖ ពេលហ្នឹង ពេលពូមកខែ២ ដល់ពេលពូមានប្រសាសន៍មិញ ខែ៣ថាពូត្រូវរបួស?

ភាព ៖ បាទ! ខែ៣ របួស ។

ដានី ៖ របួសពេលណា?

ភាព ៖ ខែ៣ ថ្ងៃ១៨ នេះត្រូវគ្រាប់នេះ ។

ដានី ៖ ត្រូវអាណាទៅ?

ភាព ៖ (បង្ហាញ) របួសនៅតាគោលតាពែក រថក្រោះបាញ់បុក ។

ដានី ៖ រថក្រោះរបស់ពួកលន់ នល់?

ភាព ៖ បាទ!

ដានី ៖ របួសនៅណា?

ភាព ៖ សមរភូមិតាគោលតាពែក ។

ដានី ៖ សមរភូមិទួលតាសេក?

ភាព ៖ តាគោលតាពែក ភូមិតាគោលតាពែក ម្ដុំដូង ម្ដុំ ។

ដានី ៖ ម្ដុំដូង?

ភាព ៖ បាទ! ភូមិធំត្រពាំងព្រះ ឃុំស្អី ខ្ញុំភ្លេចបាត់ហើយ ទៅដល់តាគោលតាពែកគេស្គាល់ ។

ដានី ៖ អូ! ដូងម៉ាជួរខាង...?

ភាព ៖ បាទ! ហ្នឹងហើយ ម្ដុំនឹង ។

ដានី ៖ ដល់ពេលពូត្រូវរបួស ពូទៅដេកពេទ្យនៅណាទៅ?

ភាព ៖ ដេកពេទ្យនៅភូមិចង្វាលវាល ពេទ្យតាជួន ជឿន ។

ដានី ៖ ដេកពេទ្យនៅចង្វាលវាល?

ភាព ៖ បាទ!

ដានី ៖ ចង្វាលវាលខាងកំពង់ឆ្នាំងអីនឹង?

ភាព ៖ បាទ! ហ្នឹងហើយ ។

ដានី ៖ ហ្នឹងដេកពេទ្យរបស់គាជួន ជឿន?

ភាព ៖ ពេទ្យគាជួន ជឿន ពេទ្យ....។

ដានី ៖ ពូដេកពេទ្យនឹងបានយូរទេ?

ភាព ៖ ៦ខែ ។

ដានី ៖ ដេក៦ខែ?

ភាព ៖ បាទ!

ដានី ៖ ៦ខែ យ៉ាងម៉េចទៀតទៅ?

ភាព ៖ ចេញពីពេទ្យ ក៏ទៅសមរភូមិខ្ញុំវិញ ។

ដានី ៖ ចេញពីពេទ្យមកសមរភូមិវិញ?

ភាព ៖ បាទ!

ដានី ៖ មកសមរភូមិណាវិញទៀត?

ភាព ៖ មកខេត្តកំពង់ ។

ដានី ៖ មកខេត្តកំពង់ដដែល?

ភាព ៖ បាទ! មកខេត្តកំពង់ដដែល ។

ដានី ៖ ហើយម៉េចទៀតទៅ ពូដល់ពេលមកសមរភូមិវិញ?

ភាព ៖ ៧៤ រវៃគ្នាទៀត ៧៤ ៧៥ ។

ដានី ៖ បាទ! ដល់ពេលខែ៣ ពូត្រូវរបួស៦ខែ វាដល់ចុង៧៤?

ភាព ៖ ខែ៣ ៧៤១ ខ្ញុំមក ។ ហើយដល់ចុង៧៤ យើងមកវិញ ជារបួសមកវិញខែវស្សាយើងមានធ្វើអី ។ ដល់ចូល៧៥បាន មើលប្រជាជនប្រមូលផល ប្រមូលអី បានវាចាប់ផ្ដើមបើកសមរភូមិគេ បើកទៀត ត្រូវរបួសទៀត ។

ដានី ៖ ត្រូវកន្លែងណាទៀត?

ភាព ៖ នេះៗ ។

ដានី ៖ ចុះម៉េចបានពូត្រូវរបួសច្រើនម៉េច? ពេលពូវៃនឹង ពូនៅសមរភូមិនៅកន្លែងវៃផ្ទាល់?

ភាព ៖ អឺ! ថាអ្នកប៉ាចទឹកដាក់គ្នា សំណាងល្អដែលយន្តហោះវាអត់ទម្លាក់ធុងសាំងមក ។

ដានី ៖ ដល់ពេលពូត្រូវរបួស ទៅដេកពេទ្យនៅចន្លាលវាលទៀត?

ភាព ៖ ពេទ្យលើកក្រោយគេផ្លាស់កន្លែង ។

ដានី ៖ ទៅណាវិញ?

ភាព ៖ អត់ស្គាល់ភូមិ មិនដឹងគេហៅភូមិ ។

ដានី ៖ ដល់ពេលដេកពេទ្យក្រោយនឹង រហូតដល់ពេលណា?

ភាព ៖ ពេទ្យដដែល១ ។

ដានី ៖ ប៉ុន្តែ ដេកពេទ្យរយៈពេលប៉ុន្មាន?

ភាព ៖ លើកក្រោយ ដូចមើលរកនឹកសិន ខែ៤១ យើងប្រុង... របួស១ខែ៣ដេកពេទ្យជាងម៉ាខែ ។

ដានី ៖ អូ!ចឹងខែ៣ឆ្នាំ៧៥ ពូត្រូវរបួសម៉ាសារទៀត?

ភាព ៖ បាទ! នឹងរបួសម៉ាសារទៀត ។

ដានី ៖ សម្រាកពេទ្យជាងម៉ាខែ?

ភាព ៖ បាទ!

ដានី ៖ រហូតដល់បែកភ្នំពេញបណ្តោយ?

ភាព ៖ បាទ! បែកចេញមក បែកនោះ ។

ដានី ៖ ដល់ពេលពូចេញពីពេទ្យមកយ៉ាងម៉េចទៅ ពេលបែកពីភ្នំពេញ?

ភាព ៖ ចូលមក យើងមកអង្គភាពយើងវិញ ។

ដានី ៖ កាលនឹងអង្គភាពពូនៅណាទៅ?

ភាព ៖ នៅមុំពេទ្យលោកសង្ឃ ផ្សារទឹកល្អក់ សាលាសន្ធរម៉ុក មុខព្រួញខ្ញុំនៅនឹង នៅសាលាសន្ធរម៉ុក នៅសម្រាក ។

ដានី ៖ ចូលមកអង្គភាព?

ភាព ៖ បាទ! អង្គភាពដដែល ។

ដានី ៖ អង្គភាពនៅពេទ្យលោកសង្ឃ?

ភាព ៖ បាទ! កងពលដដែល ។

ដានី ៖ ពេទ្យលោកសង្ឃ កាលនឹងកងពល១៤នៅនឹងម៉ង?

ភាព ៖ បាទ! កងពល១៤នៅនឹងសាលាសន្ធរម៉ុក ហឺ!វរសេនាធំ ។

ដានី ៖ វរសេនាធំរបស់លោកពូនៅសាលាសន្ធរម៉ុកម៉ង?

ភាព ៖ បាទ! នៅសាលាសន្ធរម៉ុក សម្រាកបានម៉ាខែបានទៅធ្វើស្រែ ។

ដានី ៖ សម្រាកម៉ាខែ ធ្វើម៉េចទៅ?

ភាព ៖ គេឲ្យសម្រាក ។ សម្រាករួចយើងអ្នកណាគេបោសសំអាតក្រុង ។

ដានី ៖ ម៉ាខែ?

ភាព ៖ បាទ! ខ្ញុំនៅបានម៉ាខែបានទៅកន្លែងស្រែ ។

ដានី ៖ ទៅកន្លែងណា?

ភាព ៖ ទៅធ្វើស្រែម្ដុំកប់ស្រូវ ខ្ញុំញប៉ុយ៉ាបនោះ ។ ខែ១១បានឡើងមកវិញ រៀន ហើយទៅរតនគិរីបណ្ដោយ ចុង៧៥ ។ ទៅដល់រតនគិរី ខែ១ ។

ដានី ៖ ខែ១១ ៧៥នឹងទៅរតនគិរី?

ភាព ៖ បាទ! អត់ទេ អត់ទាន់ទៅទេ ។

ដានី ៖ ទៅនៅណា?

ភាព ៖ មករៀនសិន ខែ១២បានចេញ ។

ដានី ៖ រៀននៅណា?

ភាព ៖ រៀននៅស្ពាត ។

ដានី ៖ ខែ១២ទៅរតនគិរី?

ភាព ៖ បាទ!

ដានី ៖ ទៅខែ១២?

ភាព ៖ ខែ១២ ៧៥ ។

ដានី ៖ ទៅដល់រតនគិរី?

ភាព ៖ ដល់រតនគិរីខែ១ ព្រោះយើងទៅឈប់នៅស្ទឹងត្រែងជួយច្រូតប្រជាជន ។

ដានី ៖ ចុះកងពលរបស់ពូ កងពល១៨ទៅទាំងអស់?

ភាព ៖ បាទ! ទៅដល់នោះប្រែ៨០១ ។

ដានី ៖ ចឹងពេលទៅដល់រតនគិរបានប្រែៗទៅ៨០១វិញ?

ភាព ៖ បាទ! បានប្រែ៨០១ យើងបំបែកអង្គភាពចំរុះគ្នា ខ្លះគេអ្នកណាដកទៅនៅការពារភ្នំពេញមកៗ ពួកខ្ញុំទៅនៅនឹង ។

ដានី ៖ មានគេដកការពារនៅភ្នំពេញដែរ?

ភាព ៖ បាទ! តាមអង្គភាពមួយគេរើសកម្លាំង ខ្លះទៅខាងយន្តហោះ ខ្លះទៅខាងដឹកជញ្ជូន ខ្លះទៅខាងកាំភ្លើងធំអីទៅ តែដល់ខ្ញុំអត់ទេ នៅដដែល ។

ដានី ៖ ដល់ពេលពូ ពេលទៅដល់រតនគិរីហើយ យើងមានឡើងតួនាទីអីទៀតទេ?

ភាព ៖ អនុសេនាតូចដដែល ។

ដានី ៖ នៅអនុសេនាតូចដដែល?

ភាព ៖ បាទ!... ។

ដានី ៖ ប្រធានកងពលនៅតា?

ភាព ៖ ដដែល តាសារឿន ដដែល ។

ដានី ៖ តាសារឿន គេហៅគាត់តាសារឿនចឹង?

ភាព ៖ បានហៅលេខគាត់១០៥ ។

ដានី ៖ តាសារឿន០៥?

ភាព ៖ បាទ!

ដានី ៖ ចុះតាសាន?

ភាព ៖ តាសានៗហៅសានៗ មិនដឹងលេខគាត់ប៉ុន្មាន ។

ដានី ៖ ចឹងគណៈកងពលមាន២នាក់នឹង?

ភាព ៖ បាទ! ២រូប ក្រោយមកបានៗ ហ្នឹងហើយ២ ដល់ចឹងគេដកហូតគាត់មកក្តាប់ ដែលគេដក ខាងខត្តរ ពួក...ក្បត់មេៗនឹងទៅបានឡើងទៅលើ បានឡើងតាកែវ សារឿន ។

ដានី ៖ ពេលគេដកតាសាន មកកាន់ខាង?

ភាព ៖ ខាងមណ្ឌលគិរី ។

ដានី ៖ ខាងមណ្ឌលគិរី ខាងកងពល៩២០នឹង?

ភាព ៖ បាទ! ៩២០ ។

ដានី ៖ បានដកមកកាន់ជំនួស ឈិន ដែលក្បត់នឹង?

ភាព ៖ ហ្នឹងហើយ ។

ដានី ៖ ឈិននឹងមកកាន់ ទៅបានឡើងតាកែវ សារឿនមក ។

ភាព ៖ ឡើងតាកែវ សារឿន ។

ដានី ៖ ចឹងពេលទៅដល់រតនគិរី យើងធ្វើអីទៅ កងពលយើង?

ភាព ៖ ទៅព្រំដែន ។

ដានី ៖ ទៅព្រំដែន?

ភាព ៖ បាទ! វាផ្លាស់ប្តូរគ្នា អ្នកដែលនៅទៅដល់ អ្នកណានៅធ្វើកន្លែងៗ ធ្វើរោង កាប់ចំការ ដាំស្រូវអីទៅណា ។ ហើយអ្នកទៅមុខ ដឹងទៅមុខតែម្តង ទៅដេញយួនទៀត យួនអត់ទាន់ចេញពីដីយើង ។

ដានី ៖ អត់ទាន់ចេញទេ?

ភាព ៖ បាទ! កាលខ្ញុំទៅ អត់ទាន់ចេញ កន្លែងនឹងវាតាំងពីវាសុំយើងជ្រកកោន កាលដែលវាច្បាំងយួនជើង-ត្បូង ។ នៅមុំកន្ទុយនាគនឹង សុទ្ធតែចំការដំឡូង ចំការកៅស៊ូ ។

ដានី ៖ ដល់ចឹងយ៉ាងម៉េចទៅ យើងដេញ យើងវៃវា?

ភាព ៖ អត់ទេ យើងឲ្យវាទៅ ។

ដានី ៖ ឲ្យទៅតាមធម្មតា?

ភាព ៖ តាមធម្មតា ។

ដានី ៖ អត់មានច្បាំងគ្នាអី?

ភាព ៖ អត់ទេ អត់ទាន់មានដាក់គ្នា ៧៥ យើងទៅអត់មានពិបាកបាញ់គ្នា ។ ដល់វាមករកាំរកូស ចាប់ផ្ដើម៧៧ ។

ដានី ៖ ៧៧យ៉ាងម៉េចទៅអានឹង?

ភាព ៖ ៧៧វា អានឹងពិបាក បើយើងធម្មតាទេ យើងមិនឲ្យអ្នកណាដីយើងទេ តែអ្នកឯងនៅដីយើងៗវៃហើយ ។

ដានី ៖ ដល់ពេលចឹង វៃសមរភូមិណាខ្លះទៅ?

ភាព ៖ យើងវៃៗ នៅម៉ុំអូរយ៉ាដាវ ហើយកម្លាំងវាចូលស៊ើបយើងដល់មកវើនសៃអី ពួកនោះចាប់បានៗ តែចាប់បាញ់បាន អាណាវត់គឺបាញ់ហើយ ។

ដានី ៖ រត់បាញ់ៗ ដល់ពេលយើងចាប់បាន យើងបញ្ជូនមក?

ភាព ៖ ចាប់បានសួរចម្លើយវាៗ យើងមានចេះភាសាវា ។

ដានី ៖ សួរម៉េចទៅ បើយើងអត់ចេះផង?

ភាព ៖ អត់ចេះ ចាប់បានគេបញ្ជូនមក អញ្ចេះគេដោះស្រាយ ។

ដានី ៖ បញ្ជូនមកខាងណាវិញ?

ភាព ៖ បញ្ជូនមកភ្នំពេញ ។

ដានី ៖ បញ្ជូនមកភ្នំពេញ?

ភាព ៖ បាទ!

ដានី ៖ ហ្នឹងភាគច្រើនឆ្នាំ៧៧?

ភាព ៖ បាទ! ៧៧គេចាប់ផ្ដើម ក ខ អុកឡុក រហូត៧៨ យើងទើបវៃវាបានម៉ាឆ្នាំ ។

ដានី ៖ ចុះខាងយួន មានចាប់បានយើងដែរអត់?

ភាព ៖ បានដូចគ្នា ។

ដានី ៖ ចាប់ទៅ គេយកបញ្ជូនទៅណាដែរ?

ភាព ៖ យកទៅស្រុកវា ។

ដានី ៖ ទៅស្រុកវា?

ភាព ៖ បាទ!

ដានី ៖ បើយើងអាណារត់យើងបាញ់ អាណាយើងចាប់បានយើងបញ្ជូនមកភ្នំពេញ?

ភាព ៖ ហ្នឹង អាណាវាអត់រត់យើងចាប់តាមសំរួល បើអាណាវារត់ធម្មតាទេ។

ដានី ៖ ច្រើនដែលកាលនឹង ចាប់បានច្រើន?

ភាព ៖ ចាប់បាន ហ៉េ!មិនជាច្រើនប៉ុន្មានទេ ប៉ុនយួនវៃជាមួយយើងច្រើនណាស់ យួនស៊ាប់ច្រើនណាស់។ ព្រោះធម្មតាអាណាច្រើន ស៊ានោះស៊ាប់ច្រើន អាណាតិច អានោះស៊ាប់តិច។

ដានី ៖ គ្នាច្រើន?

ភាព ៖ ច្រើនណាស់ គិតមើលពួកខ្ញុំគ្នា៦នាក់ណា ហើយវាអស់ទាស់ ប៉ុនធ្វើអីយើងមិនកើត។

ដានី ៖ ចុះពូដូចកាលនឹង យើងកងទ័ពនៅតាមព្រំដែន យើងធ្វើការជាមួយភូមិភាគមេខាងឥសាននឹងយើងធ្វើការជាមួយអីដែរ?

ភាព ៖ បាទ! ជុំគ្នា នៅខាងឥសាន អត់អី។

ដានី ៖ ពូស្គាល់យ៉ាដែរ?

ភាព ៖ យ៉ាៗ ជាឈ្មោះ យ៉ា គណៈភូមិភាគ។

ដានី ៖ គណៈភូមិភាគ ពូតែឈ្មោះទេ?

ភាព ៖ បាទ! មិនដែលឃើញទេ ឃើញៗតែគេអ្នកធំ។

ដានី ៖ កាលនឹងយើងទៅដល់ព្រំដែននឹង ដូចថាយើងដើរចេញចូលមករតនគីរី?

ភាព ៖ អត់អី ដើរបាន យើងទៅព្រំដែនសុទ្ធតែដើរកាលនោះ ចេញចូលទៅណាមកណៃបាន។

ដានី ៖ ៧៦ ខែ១ ទៅដល់នោះ?

ភាព ៖ បាទ! ខែ១ ៧៦ បានទៅដល់ៗរៀបរយធ្វើផ្ទះសម្បែង ច្រូតស្រូវ អ្នកណាកាប់កន្លែងហើយចុះនៅសុទ្ធតែព្រៃ អ្នកណាគេទៅមុខៗ។ ដល់យើងពិនិត្យមើលតាមព្រំដែន ដីរបស់យើងត្រឹមណាអីត្រឹមណា។

ដានី ៖ យើងដើរមើល?

ភាព ៖ បាទ! ដើរមើលទៅ បើយើងចូលដីគេ យើងថយមកវិញមកៗ បើអ្នកណានៅលើដីយើងយើងដេញទៅ។ យើងនិយាយតាមសម្រួល កាលនោះយើងនៅស្តាប់គ្នាបាន។

ដានី ៖ ចុះនិយាយម៉េចស្តាប់ បើយើងអត់ចេះភាសាវាផង?

ភាព ៖ អត់ចេះភាសាយើងមានអ្នកបក។

ដានី ៖ មានអ្នកបកដែរ?

ភាព ៖ អត់ៗទេ ទៅនោះសុទ្ធតែអ្នកចេះយួន ជនជាតិ។

ដានី ៖ ជនជាតិ?

ភាព ៖ ជនជាតិចេះយួន ។

ដានី ៖ ចុះពូនៅនោះរហូត?

ភាព ៖ ៣ឆ្នាំទាល់ដល់៧៩ មើលខ្ញុំរបួស៧៨ ខែ១០ ។

ដានី ៖ ខែ១០?

ភាព ៖ បាទ! ដល់ខែ១០ ៧៨ ខ្ញុំជិះយន្តហោះមកដេកពេទ្យភ្នំពេញ ដល់ចូល៧៩ជិះរទេះភ្លើងមក ក៏ធ្លាក់ដីថៃ ។

ដានី ៖ កាលនឹង ៧៨ ពូត្រូវរបួសត្រង់ណា?

ភាព ៖ នេះដៃ ធ្វន់បណ្ដោយ ពិការបណ្ដោយ ។

ប្រពន្ធ ៖ ដើងនោះខ្ទាំង បត់អត់បាន ។

ភាព ៖ នេះកាលជាមួយលន់ នល់ របួសដែរ តែអត់ពិការ ។ អានេះយួនអី ចុះបើវាតាំងពីព្រលឹម មិនទាន់បើកភ្នែក ទាល់គ្នាថ្ងៃលិច វាធ្វើអីយើងមិនកើត បើវ៉ៃគ្នារហូត ។ ពួកខ្ញុំ តែ៦ត្រង់ សេរ ។

ដានី ៖ តែ៦នាក់?

ភាព ៖ បាទ! ៦ត្រង់សេរ ម៉ាត្រង់សេរ៣នាក់ ហើយដល់ចឹងវាធ្វើអត់បែក ។ ដល់ចឹងវាចាញ់ទៅ ព្រឹកឡើងយើងទៅប្រមូលបានគ្រាប់បែក បានទឹកវាដឹកសុទ្ធទឹកតែ ហើយចឹងអត់មានអ្នកណា ដាក់មីន វាឲ្យយើងទៅ ។ អត់ណា១ ទៅខ្លួនឯង ដល់ទៅនៅសល់ម៉ាគ្រាប់ជិតហើយ អា អ្នកយាមខ្ញុំគេថា "បងយួន" "យួនឯងមិនគិតបាញ់ ចាំបាច់ប្រាប់" ។ ដល់អាអ្នកយួនដែល វាចាញ់យើងនឹង វាថាគេទៅអស់ វាដូចថាវង្វេង ដល់ចឹង វាភ្ញាក់ឡើងវាបាញ់ខ្ញុំដាំង វារត់ ខ្ញុំទាញគ្រាប់បែកម៉ាគ្រាប់ ថា "ឯងចុយម៉ែ ឯងចិត្តស្មើង រត់ហើយ" វាអត់ហ៊ានសំរុកមក យើង តែបាញ់ហើយវារត់ ។ តែមកគឺគ្នាខ្ញុំ២នាក់ វាក៏២នាក់ គ្រាប់បែកនៅនឹងដៃ យើង ផាប់ទាំងអស់គ្នា ពួកនោះដាច់ខាតណាស់កាលនោះ ពួកនោះអត់បាន ។ ព្រោះពួកកងពិសេស វ៉ៃសុទ្ធតែមានគ្រាប់បែក ។

ដានី ៖ ចឹងកាលនឹងដល់ពេលវាបាញ់ត្រូវពូ អាអ្នកនេះវាបាញ់?

ភាព ៖ បាទ! យួនវាបាញ់ៗសុវ៉ានណៃម៉ាដើម អាការម៉ាដើម ប៉ុនសុវ៉ាន់ណៃអត់ធ្លាក់ជិតទេ វា បាញ់ត្រូវអាការទេ ។

ដានី ៖ អាការទេអានេះ?

ភាព ៖ បាទ! អាការទេ ។ អានេះគ្រាប់អត់ផ្ទុះ អានេះគ្រាប់ផ្ទុះ ។

ដានី ៖ គ្រាប់ផ្ទុះម៉េច?

ភាព ៖ គ្រាប់ផ្ទុះនឹង គឺថាគ្រាប់ក្តក់ៗ កាលណាគ្រាប់ គេដាក់ឆ្លាស់គ្នា ៣គ្រាប់គេដាក់អាផ្ទុះមួយៗ វាមានរលូតក្បាលវា ។

ដានី ៖ ដល់អានេះត្រូវអាការដែរ?

ភាព ៖ បាទ! អាការដែរ ចុះវាបាញ់ រ៉ាំរ៉ាល់ៗវាចេញ៣គ្រាប់ ។

ដានី ៖ អានេះត្រូវម៉ាគ្រាប់?

ភាព ៖ បាទ! ម៉ាគ្រាប់វាផ្ទុះមកបណ្តោយ ។

ដានី ៖ ឆ្ងាយមក?

ភាព ៖ បាទ! ឆ្ងាយ វាបាញ់រ៉ាំរ៉ាល់ ត្រូវទាំងអស់ ព្រោះជើងខ្ញុំលុតជង្គង់ ត្រូវចេញពីនេះទៅបាត់ទៅ អានេះចូលផ្សេងទៀត ។ វាប៉ាញ់រ៉ាំរ៉ាល់ សុវ៉ាន់ណៃ វាបាញ់គ្រាប់សំដៅក្បាល ។

ដានី ៖ ត្រូវពេលណា?

ភាព ៖ ពេលព្រឹក ។

ដានី ៖ ពេលព្រឹក ថ្ងៃ?

ភាព ៖ ថ្ងៃ២៨ ខែ១០ ហ្នឹង ។

ដានី ៖ ខែ១០ ៧៨?

ភាព ៖ ២៨ ខែ១០ ៧៨ ។

ដានី ៖ ដល់ពេលចឹងគេដាក់យន្តហោះពូ?

ភាព ៖ ដាក់យន្តហោះ ។

ដានី ៖ ដាក់យន្តហោះ ពីរតនគិរី មកដេកពេទ្យណា?

ភាព ៖ បាទ! មកដេកពេទ្យភ្នំពេញ ។

ដានី ៖ ពេទ្យនៅណា?

ភាព ៖ ពេទ្យ៩៨ ពេទ្យមុនីវង្ស ។

ដានី ៖ ពេទ្យមួយណា?

ភាព ៖ ពេទ្យមុនីវង្ស ។

ដានី ៖ ពេទ្យមុនីវង្ស ពេទ្យព-៩៨?

ភាព ៖ បាទ! ពេទ្យព-៩៨ ពេទ្យរបស់សេនាធិការ ។

ដានី ៖ ពូដេកពេទ្យនឹងបានរយៈពេលប៉ុន្មានដែរ?

ភាព ៖ មិនដឹងបានប៉ុន្មានទេ ដូចដើរបានតិចៗហើយ ។ មើលពីខែ១០ ខែ១១ ខែ១២ បាន២ខែ គិតទៅ មិនបាន២ស្រួលទេ ព្រោះថ្ងៃ៦រត់ ។

ដានី ៈ ថ្ងៃ៦មករាហ្នឹង?

ភាព ៈ បាទ! ព្រឹកឡើងថ្ងៃ៧ ថ្ងៃ៦ពេទ្យសែងយើងដាក់រទេះភ្លើង មកចុះនៅនឹងថ្មគោល ។

ដានី ៈ កាលនឹងពូមានគ្រួសារនៅ?

ភាព ៈ នៅទេ ។

ដានី ៈ ចឹងពេលដែលយួនចូលឆ្នាំ៧៩ ពូជិះរទេះភ្លើងពីភ្នំពេញមក?

ភាព ៈ បាទ! ចុះមកថ្មគោល ដើរធ្លាក់ប៉ៃលិន ចេញពីប៉ៃលិនមកសំឡូត ចេញពីសំឡូតមកៗយើងលាចនេះ តាមផ្លូវនេះមោង គិរី ក្បាលគោ អូរសោម ធ្លាក់ថ្មដារ នៅជំរំនឹងបណ្ដោយ ។

ដានី ៈ ចឹងពូពេលដែល តាំងពីពូចេញពីផ្ទះឆ្នាំ៧១រហូតដល់៧៩ ពូមានធ្លាប់ទៅលេងផ្ទះវិញទេ?

ភាព ៈ អត់ដែលរហូត ។

ដានី ៈ អត់ដែរ?

ភាព ៈ បាទ! អត់ទេ រំដោះថ្ងៃ៧៥ ក៏អត់បានទៅដែរ ។

ដានី ៈ ម៉េចចឹងពូ បានអត់ទៅលេង?

ភាព ៈ យើងអត់បានសុំគេៗអត់ថាអី យើងសុំគេៗឲ្យទៅ ។

ដានី ៈ ពូអត់សុំ?

ភាព ៈ ប៉ុនដូចថាខ្ជិលអីដង បើយើងសុំគេៗឲ្យទៅដែរ ខ្លះគេអត់ទេ គេឲ្យទៅ ខ្ញុំខ្ជិល នឹកឃើញចាំទៅដល់នោះហើយ ។ ចាំទៅដល់នោះ ហើយក៏ជាប់តដៃទៀត ។ ដល់តដៃ មេៗខ្ញុំប្រាប់ដែរថាយើងមិនបានយូរទេ មិនដល់វ៉ៃពាឆ្នាំ យើងវ៉ៃទៀតហើយ ជាមួយយួនទៀតនឹងម៉ង ។

ដានី ៈ គេថាចឹង?

ភាព ៈ គាត់ប្រាប់ចឹង ប៉ុនចេះប្រាប់ទាំងអស់ ។

ដានី ៈ ចឹងពេលពូមកជិះរទេះភ្លើងមកៗចុះនៅបាត់ដំបង?

ភាព ៈ បាទ! ចុះថ្មគោល ។

ដានី ៈ ចុះថ្មគោល ចេញពីថ្មគោល?

ភាព ៈ ចេញពីថ្មគោល បានធ្លាក់ទៅប៉ៃលិន ។

ដានី ៈ កាលនឹងពូដើររួចខ្លួនឯង?

ភាព ៈ ដើរឈើច្រត់ដើរបាន តែរបួសអត់ទាន់ជាងទេ ។

ដានី ៈ បាទ! ប៉ុន្តែយើងដើរខ្លួនឯងក៏បាន?

ភាព ៈ បាទ! ដើរបាន ដើររហូត ។

ដានី ៈ ដើរពីថ្មគោលទៅដល់ប៉ៃលិន?

ភាព ៖ បាទ! ចេញពីប៉ៃលិន ។

ដានី ៖ រយៈពេលប៉ុន្មានទៅបើយើងទៅ?

ភាព ៖ អូ! រាប់ខែ រាប់មិនអស់ ។

ដានី ៖ ព្រោះយើងត្រូវរបួសចឹង យើងដើរបានតិចៗ?

ភាព ៖ បាទ! ដើរបានតិចៗ ថ្នាំយើងសុំពេទ្យគេលេប ។ ខ្ញុំនៅជាមួយពេទ្យ អត់ឲ្យបែកពីពេទ្យទេ ។

ដានី ៖ ចុះអ្នកគេល្អ គេអត់ត្រូវរបួសអី គេដើរទៅមុនទៅ?

ភាព ៖ បាទ! អ្នកអត់ត្រូវរបួសខ្លះក៏គេទៅផ្ទះទៅ ខ្លះក៏គេដើរមកមុនមក ភាគច្រើនគេមកតាមអន្លក់ ភាព ខ្លះគេជួបអន្លក់ភាពគេទៅ ។ ហើយដល់ពួកខ្ញុំនៅជាប់នឹងពេទ្យ ដល់បែកពេទ្យចេញពីយើងនេះ ក្រវាំញយើងសព្វថ្ងៃគេហៅ យើងមកខាងលាច ដល់ចឹងបែកពីពេទ្យបណ្តោយ ។

ដានី ៖ ពេលនឹងពូជាដាច់ហើយ?

ភាព ៖ អត់ទាន់ជាទេ ដល់ខ្ញុំទៅជានៅថៃ ខ្ញុំទៅដេកពេទ្យថៃម៉ាខែ ។

ដានី ៖ ទៅដេកពេទ្យថៃម៉ាសារទៀត?

ភាព ៖ បាទ!

ប្រពន្ធ ៖ ឡើងកកដៃនឹង នឹងហើយដៃបាក់នឹង មិនឆ្អឹងជាប់គ្នាណា ជាប់តែសាច់ទេ ឆ្អឹងអត់ជាប់គ្នា ។

ភាព ៖ ទៅដេកពេទ្យនៅជិរំទៀត ។

ដានី ៖ ពូកាន់ស្លាបព្រា កាន់អីកើតទេ?

ភាព ៖ អត់កើតទេក្មួយ ដៃបានដៃខាងនេះទាំងអស់ ស្អី មុនយើងប្រើដៃនេះ ។

ដានី ៖ កាលមុនយើងប្រើដៃស្តាំ?

ភាព ៖ បាទ! ដៃស្តាំ ។

ដានី ៖ ចឹងដៃនេះប្រើការអត់កើតទេ?

ភាព ៖ ដៃនេះបានតែទប់ទេ ព្រោះអត់ដៃនេះ ក៏ធ្វើអីអត់កើតដែរ ជិរះស្មៅ កាន់ត្បូងចប ។

ដានី ៖ ចឹងដល់ពេលពូមកដល់លាចហើយ យ៉ាងម៉េចទៀតបានបន្តពីលាចមកណាមក ឡើងទៅប៉ៃលិន?

ភាព ៖ បន្តពីលាចទៅ ធម្មតាយើងចេញពីប៉ៃលិនយើងមកសំឡូត ចេញពីសំឡូតបានមកលាច ។

ដានី ៖ រយៈពេលប៉ុន្មានទៅ?

ភាព ៖ អូ! រាប់ខែ សុទ្ធតែរាប់ខែ ។

ដានី ៖ កាលនឹងយើងដើរជាមួយពីណាគេ?

ភាព ៖ ដើរអន្លក់ភាពនៅក្នុងពេទ្យ នៅជាមួយពេទ្យ ។ យប់ត្រង់ណាដេកត្រង់ ។

ដានី ៖ ដេកនៅក្នុងព្រៃក្នុងអីនឹង?

ភាព ៖ បាទ! អត់មានដឹង អន្រើងមួយព្រៃត្រង់ណាក៏ដោយ អត់ឃើញ ។ ៧៩ វេទនាណាស់ វេទនាម៉ុំនេះ ។

ដានី ៖ ចុះមានទទឹករហូត?

ភាព ៖ ទទឹករហូត វេទនា ។

ដានី ៖ វេទនាខ្លាំងម៉ង?

ភាព ៖ អូ! មិនថាប្រជាជន មិនថាក្រសួងមន្ទីរ ស្លាប់ៗច្រើនណាស់ ស្លាប់នឹងអត់បាយ ច្រើននឹងអត់បាយ រត់ទៅថៃ ។

ដានី ៖ ដល់ពេលចេញពីលាចមក ពូទៅណាទៀត?

ភាព ៖ នេះ ទៅថៃបណ្តោយ ។

ដានី ៖ ចូលថៃ អានឹងគេហៅអីគេ?

ភាព ៖ អានេះចូលម៉ុំយើងចំការសៅម៉ៅ កន្លែងស្ពាននឹងគឺថ្មមួយដើម ។

ដានី ៖ ជំរំហើយអីគេ?

ភាព ៖ ជំរំម៉ៃរូត ខៅឡាន ។

ដានី ៖ ជំរំខៅឡាន ។ ចឹងដល់ពេលពូទៅដល់ជំរំនឹង ពូទៅដេកពេទ្យម៉ាសារទៀត?

ភាព ៖ បាទ! ទៅដេកពេទ្យ ចេញពីពេទ្យមកយើងវិញ ចេញពីយើងបានទៅជំរំដដែល ។

ដានី ៖ ដេកពេទ្យរយៈពេលប៉ុន្មាន?

ភាព ៖ ដេកពេទ្យម៉ាខែ ។

ដានី ៖ ម៉ាខែហើយ បានចេញមកណាវិញ?

ភាព ៖ បាទ! បានចេញពីយើងនេះ បានធ្លាក់មកប៉ៃលិន ចេញពីប៉ៃលិនមកត្រាំង អូរអន្លក់ មកចូលជំរំនេះបណ្តោយ ចេញពីជំរំឡើងមកនៅនេះរហូត ។ ២សារ ។

ដានី ៖ ពូទៅដល់ថៃឆ្នាំប៉ុន្មានទៅ ដល់ថៃ?

ភាព ៖ ៧៩៦ ។

ដានី ៖ ៧៩ ដដែល?

ភាព ៖ បាទ! ៧៩ ដដែល ។

ដានី ៖ ប្រហែលខែប៉ុន្មាន?

ភាព ៖ មើល៧៩ ខែ៤ ។ អូរដាច់ខែ៤ហើយ ព្រោះចូលឆ្នាំខ្មែរយើងចូលនៅនឹងលាច ។ អត់បានចូលទេ រត់ម៉ាខែត្រឹម ចេញពីលាចខែ៤ រហូតដល់ខែ៥ថ្ងៃ៥ បានខ្ញុំដល់ថៃ ម៉ាខែ ៥ថ្ងៃ ។

ដានី ៖ ដល់ពេលនៅថៃបានរយៈពេលប៉ុន្មាន បាន?

ភាព ៖ បានម៉ាខែ ។

ដានី ៖ បានម៉ាខែ បានត្រឡប់ចូលមក?

ភាព ៖ ចូលមកដីយើងវិញ ឡានថៃដឹកមក ។

ដានី ៖ ឡានថៃដឹកមកដល់ប៉ៃលិន?

ភាព ៖ បាទ! ដាក់មកយើងវិញ ។

ដានី ៖ ពូនៅប៉ៃលិន ពូនៅក្នុងអង្គភាពអី?

ភាព ៖ អង្គភាពអ្នកពិការ ។

ដានី ៖ អង្គភាពអ្នកពិការគ្នាច្រើន?

ភាព ៖ ពិការច្រើន ៣០០-៤០០នាក់ ។

ដានី ៖ ចុះគេឲ្យធ្វើអីទៅ យើងពិការ?

ភាព ៖ អត់មានធ្វើអី ។ ចុះមានអី កាលនោះអង្ករៗយើងអត់ទាន់ត្រូវរូវគ្នាទេកាលនឹង អង្ករម៉ាពេល អត់បានកន្ទះកំប៉ុង ។ អត់បានកន្ទះទេ ក្នុងកន្ទះកំប៉ុងត្រូវម៉ាថ្ងៃ ។

ដានី ៖ ដល់ពេលពូនៅប៉ៃលិនរយៈពេលប៉ុន្មានទៅបានចេញ?

ភាព ៖ ដឹងប៉ុន្មាន ដល់ខែ៨ ខែ៩ បានឃួនរ៉ៃម៉ាសារទៀត ធ្លាក់ដល់ដីថៃៗដឹកដាក់ជំរំបណ្ដោយ ។

ដានី ៖ ដាក់ជំរំណាទៅ?

ភាព ៖ ជំរំម៉ៃរូត ។

ដានី ៖ ម៉ៃរូច?

ភាព ៖ ហៅម៉ៃរ៉ូត ។

ដានី ៖ ម៉ៃរ៉ូតនឹង ជំរំយ៉ាងម៉េច?

ភាព ៖ ជំរំជនភៀសខ្លួន មនុស្សរាប់ម៉ឺននាក់ ។

ដានី ៖ នៅណា?

ភាព ៖ នៅសមុទ្រយើង ចុះពីថ្មដារទៅ ជិតកួងយៃ ។

ដានី ៖ ថ្មដារយើង?

ភាព ៖ បាទ! ថ្មដារយើង ។

ដានី ៖ ជិតកួងយៃ ដល់ពេលពូនៅជំរំរយៈពេលប៉ុន្មានទៅ?

ភាព ៖ ដឹងប៉ុន្មានបានខ្ញុំឡើងវិញ ៧០ ៨១ បានខ្ញុំឡើង ។

ដានី ៖ ដល់ពេល៨១ពូឡើងមកណា?

ភាព ៖ ឡើងមកថ្មដារ ។

ដានី ៖ ឡើងមកថ្មដារយើង?

ភាព ៖ បាទ! ថ្មដារយើង ។

ដានី ៖ ថ្មដារ ពូនៅខាងអីវិញ?

ភាព ៖ នៅកន្លែងពិការរហូត ។

ដានី ៖ នៅថ្មដារបានយូរទេ?

ភាព ៖ បានប៉ុន្មានខែ មិនបានម៉ាខែ ។

ដានី ៖ អត់បានម៉ាខែ?

ភាព ៖ បាទ! ឡើងមកៗនៅអង្គភាពខ្ញុំចាស់វិញដដែល ។

ដានី ៖ អង្គភាពចាស់នៅណា?

ភាព ៖ នៅចំការស្រូវ ។

ដានី ៖ ចំការសេរី?

ភាព ៖ គេហៅចំការស្រូវ ។

ដានី ៖ ចំការស្រូវនឹង?

ភាព ៖ ចំការស្រូវ យើងច-១ ។

ដានី ៖ នៅណាទៅ?

ភាព ៖ ថ្មដារដែរ ប៉ុនខាងនេះថ្មដារ ។

ដានី ៖ ពូនៅកន្លែងអង្គភាពពិការដដែល?

ភាព ៖ បាទ! នៅពិការដដែល ពិការ ពួកខ្ញុំគ្នាតិច ។

ដានី ៖ ចុះពូបានជួបមីងឆ្នាំណា?

ភាព ៖ ឆ្នាំ៨១ ។

ដានី ៖ ចឹងពូរៀបការឆ្នាំ៨១?

ភាព ៖ បាទ!

ដានី ៖ ដល់ពេលពូរៀបការហើយយ៉ាងម៉េច ពូនៅក្នុងអង្គភាពពិការ?

ភាព ៖ បាទ! នៅក្នុងអង្គភាពពិការដដែល ពួកខ្ញុំអ្នកពិការរហូត ។

ដានី ៖ ហើយចឹងនៅរហូតដល់ពេលណាទៅ?

ភាព ៖ រហូតដល់យើងសមាហរណកម្ម មានដែលទៅណា ។

ដានី ៖ ប៉ុន្តែយើងពិការ យើងអត់ធ្វើអីទេ?

ភាព ៖ បាទ! អត់ធ្វើអី ។

ដានី ៖ យើងមានរបប?

ភាព ៖ បាទ!

ដានី ៖ ពីណាគេអ្នកគ្រប់គ្រងពិការ?

ភាព ៖ អ្នកគ្រប់គ្រងរួមខ្មោច តាកែន ស្លាប់បាត់ហើយ ។

ដានី ៖ គាត់ឈ្មោះអីគេ?

ភាព ៖ ឈ្មោះ តាកែនៗ ។

ដានី ៖ តាកែន ។

ភាព ៖ គាត់ជនជាតិ ។

ដានី ៖ គាត់ជនជាតិដែរ?

ភាព ៖ បាទ! ជនជាតិដែរ ។

ដានី ៖ អូ! ជនជាតិច្រើនអ្នកធ្វើធំៗ?

ប្រពន្ធ ៖ ជនជាតិចិន ខ្មោចបងកែននឹង គាត់នៅជាមួយ ។

ភាព ៖ គាត់ពីមុនក្រសួង៨៧០ ។

ដានី ៖ ពូស្គាល់ ៨៧០?

ភាព ៖ បាទ! ៨៧០ ដែលចាប់ ប៉ង់ ហើយ គាត់ឡើងជំនួស ។

ដានី ៖ ចាប់ប៉ង់ហើយ គាត់ឡើងជំនួស តាកែន?

ភាព ៖ ហ្នឹង តាកែន អ្នកឡើង ។

ដានី ៖ កាលជំនាន់ពាន្ឆាំ ពូស្គាល់មន្ទីរ៨៧០ដែរ?

ភាព ៖ អត់ដែលនៅនឹងផង ទើបនៅក្រោម ។

ដានី ៖ បាទ?

ភាព ៖ ទើបមកនៅយើងឆ្នាំ៨១ ។

ដានី ៖ ៨១ មានគេហៅមន្ទីរ៨៧០ដែរ?

ភាព ៖ បាទ! ពីមុនមកវា៨៧០ ។

ដានី ៖ ដល់ក្រោយមកគេហៅអីវិញ?

ភាព ៖ បាទ! ដល់ក្រោយមក មិនដឹងគេហៅលេខប៉ុន្មាន ខ្ញុំភ្លេចបាត់ហើយ ។

ដានី ៖ ចុះពូស្គាល់ប៉ង់ដែរ?

ភាព ៖ ប៉ង់ គណៈ៨៧០ ។

ដានី ៖ គណៈ៨៧០ កាលពីជំនាន់នឹង ប៉ុន្តែពូ?

ភាព ៖ អត់ដែលបានជួបគ្នាទេ ។

ដានី ៖ ចុះម៉េចបានពូដឹងថា គេចាប់ប៉ង់?

ភាព ៖ គេចាប់នៅឆ្នាំ៧០ប៉ុន្មាន ខ្ញុំភ្លេចបាត់ហើយ ។

ដានី ៖ ប៉ុនពីមុនមក អត់ដែលស្គាល់ប៉ង់ទេ?

ភាព ៖ អត់ទេៗ ឮតែឈ្មោះ ។

ដានី ៖ ឮតែឈ្មោះ?

ភាព ៖ បើមេៗខ្ញុំគាត់ស្គាល់ ។

ដានី ៖ គេថាគេចាប់ប៉ង់ចាប់អីទៅនឹង ពូឮតាមគេនិយាយ?

ភាព ៖ ឮៗគ្រាន់ឮ បើថាឲ្យឃើញផ្ទាល់ភ្នែកអត់វហូត ។

ដានី ៖ អត់ គ្រាន់ដឹងថា?

ភាព ៖ គ្រាន់ដឹងថាគេចាប់ ។

ដានី ៖ គ្រាន់ដឹងថា ពេលគេចាប់ប៉ង់ហើយ បានតាកែននឹងគាត់ឡើងប្រធានមន្ទីរ៨៧០?

ភាព ៖ គាត់ឡើងប្រធានមន្ទីរជំនួស ។ ហើយគាត់ថា កុំតែគាត់ឡើងជំនួសទាន់ កុមារកំព្រាម៉ាម៉ឺននាក់ គេវៃចោល ។ គាត់ដឹងទាន់ៗវាជ្រុលបាត់ហើយ នៅបូព៌ា ។

ប្រពន្ធ ៖ មកពីនៅបូព៌ាកុមារជំទង់ៗអាយុប្រហែល១៨ ១៩ ប្រហែល១៥នឹង ម៉ាម៉ឺននាក់ជាង រួចគេយកមក ហើយបានគាត់កាលនឹងធ្វើសំបុត្រទាន់ បានយកបាន ហើយនឹងគេយកទៅវៃចោលហើយ ។ ហើយអត់ដឹងអីសោះ កុមារនឹងនៅតូចៗ អត់ដឹងអី វាអត់ដឹងអី សួរវាអត់ដឹងអីទេ ។

ភាព ៖ មានរឿងរ៉ាវ ទម្រាំតែដឹង ។ ហើយពួកខ្ញុំនេះ សុទ្ធតែមកដេកពេទ្យភ្នំពេញ ចឹងសោះអស់ទេរ ។

ដានី ៖ ចុះពូកាលនឹង អត់មានដែរដឹងថា ជំនាន់៣ឆ្នាំ មានការចាប់ សម្លាប់?

ភាព ៖ អត់ៗ ដឹង ។

ដានី ៖ ចុះពូក្រែងពូដឹងហើយថា កាល៩២០ ឈ្មោះ ឈិន?

ភាព ៖ ទេ! ឮតែគេថា ។

ដានី ៖ ថាក្បត់?

ភាព ៖ បាទ! ឮថាក្បត់ គ្រាន់ឲ្យឮ ឲ្យថាចាប់គេផ្ទាល់ដៃ អត់ ។

ដានី ៖ ចុះកែវ សារឿនអី កែវ សារឿនគេចាប់ដែរ?

ភាព ៖ កែវ សារឿន ទោះបីក៏គេចាប់ ក៏គេអត់ចាប់នៅ គេហៅមកភ្នំពេញ ។

ដានី ៖ មកនៅភ្នំពេញទៅបាត់ទៅ?

ភាព ៖ ហ្នឹងគេចាប់តែមេៗ ។ បើថារឿងគេចាប់ រឿងអ្នកធំ អត់ចេះខុស គេច្រើនតែចេះរបស់របរបើកឲ្យទៅប្រជាជន ឬ ចាក់ទឹកអាស៊ី ឬខាងសមុទ្រដាក់ទឹកសមុទ្រ ។ អង្គរអីរាប់គោនទម្រាំតែយើងដឹងទាន់ ។

ដានី ៖ ចុះកែវ សារឿន គាត់ម៉េចដែរ បើតាមពូដឹង?

ភាព ៖ កែវ សារឿន មានបញ្ហាអីពីរឿងសីលធម៌ តូចតាច រឿងមិនជាក្បត់ជាតិ ។

ដានី ៖ សីលធម៌កាលគាត់នៅរតនគីរី?

ភាព ៖ បាទ! នឹងហើយនៅរតនគីរី ឬមួយក៏និន្នាការអីក៏មិនដឹង ប៉ុនតានឹងខិលអារឿងស្រី ព្រោះនៅកងនោះ ភាគច្រើនគឺល្អអត់ដែលអីទេ ។ ទោះបីអ្នកជាប់ពីអតីតកាលមកម៉េចៗក៏អត់ចេះអី ខ្លាចតែនៅក្រៅ ទោះបីអ្នកខ្លះជាទាហានលន់ នល់ក៏ដោយ អ្នកនៅជាមួយខ្ញុំក៏មិនអីទេ ។

ដានី ៖ ចុះតាសាន?

ភាព ៖ បងសាន គាត់កាលពីមុនថ្នាក់ទី១ អត់មានអីទេ អត់ជាប់ទេ ។

ដានី ៖ អត់ជាប់ទេ?

ភាព ៖ បងសាន គាត់ទើបនឹងស្លាប់ ។

ដានី ៖ គាត់ទើបនឹងស្លាប់?

ភាព ៖ ទើបស្លាប់យើងក្រោយសមាហរណកម្ម ធិន នេះក៏ដូចគ្នា ។

ដានី ៖ ពីណា?

ភាព ៖ ធិនៗ ។

ដានី ៖ ធិន នឹងគាត់ធ្វើអីដែរ?

ភាព ៖ គាត់ពីមុនវរៈសេនាធំខ្ញុំ វរសេនាតូចខ្ញុំរហូត បានគាត់ឡើងវរសេនាធំ ចេញពីវរសេនាធំបានឡើងកងពល ។ ដល់ចេញពីកងពល គេដកទៅធ្វើគណៈតំបន់១០១ នៅភូមិភាគឥសាន ។

ដានី ៖ គាត់ធ្វើគណៈតំបន់?

ភាព ៖ បាទ! ចេញពីគណៈតំបន់ ដល់ចឹងយើង៧៩រត់មក គាត់ចូលទ័ពទៀត ។

ដានី ៖ ឈ្មោះ ធិន?

ភាព ៖ បាទ!

ដានី ៖ ធិន គាត់គណៈកងពលនៅ?

ភាព ៖ បាទ! ៨០១ដែរ ។

ដានី ៖ ៨០១ដែរ ហើយគេដកគាត់មកធ្វើគណៈតំបន់ ។ ចុះពេល យ៉ា គេ?

ភាព ៖ យ៉ា អត់ទេ យ៉ា ដាច់ដោយឡែក ។

ដានី ៖ បាទ! យ៉ា គេចាប់ហើយ គេមានបង្កើតដាក់គណៈតំបន់អីថ្មីអត់?

ភាព ៖ យី! ខាងប្រជាជនខ្ញុំអត់ដឹងផង ព្រោះយើងមួយជាទ័ព មួយខាងប្រជាជនស្រេចគេខាងស្រុកខាងខេត្តគេ ។

ដានី ៖ ចុះតាសាន ប្រពន្ធគាត់ឈ្មោះអីដែរ?

ភាព ៖ តាសាន ឈ្មោះ វីន ។

ដានី ៖ ឈ្មោះ មីង វីន?

ភាព ៖ បាទ! ឈ្មោះ វីនៗ គាត់ពីមុនកងនារី កងវរៈសេនាធំរបស់វរៈ ធម្មតាកងពលនីមួយៗវាតែងតែមានកងនារីសម្រាប់ដឹកជញ្ជូនក្រោយៗ ។

ដានី ៖ គាត់ខាងកងនារី?

ភាព ៖ បាទ!

ដានី ៖ គាត់ធ្វើប្រធានពេទ្យ?

ភាព ៖ អត់ទេ វីន គាត់ខាងកងនារី ។

ដានី ៖ ពូស្គាល់គាត់ច្បាស់ដែរ?

ភាព ៖ នៅអង្គភាពជាមួយគ្នា ។

ដានី ៖ នៅអង្គភាពកាលណា ៨០១?

ភាព ៖ តាំងពីយើង៧៥ ។

ដានី ៖ ៧៥?

ភាព ៖ បាទ! ដល់ក្រោយមក៧៩ អត់ដែលបានជួបគ្នារហូត ។

ដានី ៖ អត់ដែលបានជួប?

ភាព ៖ បាទ! ចុះគាត់នៅកន្លែងកងពល ហើយខ្ញុំនៅមុខ វាឆ្ងាយគ្នា គាត់មើលពីកន្លែងកងពលនៅឧទាហរណ៍ថានៅនេះ ហើយទ័ពនៅព្រំដែនថ្មដារ ។ អត់ដែលបានជួបទេ ពូកខ្ញុំម៉ាខែ ឡើងមករៀនម្ដង ក៏មិនដែលបានជួបគាត់ ។

ដានី ៖ ចុះកាលជំនាន់នឹង ពូមិនដែលដឹងថានៅខាងក្រៅខាងក្រោយម៉េចៗទេ?

ភាព ៖ អត់ដឹងទេ បាទ! អត់ដឹង ។ ដឹងនិយាយអាណាកាប់សម្លាប់ម៉េចៗ អត់មានដឹង ។

ដានី ៖ ចុះពូដល់ពេលឆ្នាំ៨១ បានជួបមីង?

ភាព ៖ បាទ!

ដានី ៖ ពេលនឹងម៉េចបានជួបគ្នា?

ភាព ៖ គេនៅខាងដីកជញ្ជូន ។

ប្រពន្ធ ៖ ខ្ញុំនៅខាងដីកជញ្ជូន ហើយខ្ញុំយើងរត់ដូចគ្នាចូលជំរំដូចគ្នា ហើយដល់មកខាងដីកជញ្ជូននឹង ។

ភាព ៖ ឡើងពីជំរំមក ខ្ញុំជួបកងចាស់ពីមុនមក ។ កងចាស់ ពួកខ្ញុំនៅកន្លែងតា១ ។

ដានី ៖ កន្លែងតា១?

ភាព ៖ បាទ!

ដានី ៖ កងចាស់របស់ពូ?

ភាព ៖ បាទ!

ដានី ៖ កងចាស់ យ៉ាងម៉េច?

ភាព ៖ កងចាស់ ទ័ពចាស់យើង ព្រោះមេ១ខ្ញុំកងការពារគាត់ ។ ដល់យើង៧៩រំដោះមក ដកយកពួកនឹងការពារតា១ ។ ដោយឡែកតែខ្ញុំទៅនៅរតនគិរីទៅ ។

ដានី ៖ ពីណាខ្លះ ដែលកងការពារតា១?

ភាព ៖ កងការពារ មានណា ពីមុនមកមាន តាពា ឡឺ ធិន ខ្មោចតាកែនអី ។

ដានី ៖ តាថែម?

ភាព ៖ តាកែន ស្លាប់ហើយ ។

ដានី ៖ ប៉ុន្តែកាលនឹង គាត់មកកងការពារតា១នឹង ក្រោយ៧៩?

ភាព ៖ បាទ! អាខ្លះកងការពារវាមិនចេះបាននៅរហូតទេ ។ យើងនៅជាមួយគាត់ទៅបានម៉ាឆ្នាំ ២ឆ្នាំ គេដកឲ្យទៅកាន់កងកាន់អីទៀតណា ដូរគ្នាចុះឡើង ។

ដានី ៖ ចុះពូដល់ពេលពូរៀបការហើយ ពូយ៉ាងម៉េច ពូនៅកង?

ភាព ៖ បាទ! នៅក្នុងពិការ ។

ដានី ៖ ក្នុងពិការដដែល ហើយមីងនៅ?

ភាព ៖ នៅជាមួយគ្នា ចេញពីដីកជញ្ជូនមកនៅអ្នកពិការ ។

ប្រពន្ធ ៖ យើងចេញពីដីកជញ្ជូនមកនៅខាងកន្លែងពិការនេះ ។ ហើយក្រោយមក នៅកន្លែងពិការនឹង នៅអ៊ំកែននឹង គេហៅម្តុំជិតកង១តា១ កងការពារតា១នឹង ។

ដានី ៖ ចុះពូដល់ពេលនៅនឹងរហូតដល់ពេលណាទៅ យើងមកនៅ.

ភាព ៖ យើងមកនៅសំឡូតនេះ ។

ដានី ៖ អត់ទេ ចេញពីកន្លែងពិការហើយ?

ភាព ៖ ចេញពីនោះ គ្រាប់ផ្លោងនៅ......ខ្ញុំរត់ទៅសំឡូត ដោយសារគ្រាប់ផ្លោងចេញពីក្បាលឡាន ។

ដានី ៖ ក្បាលឡាននៅណាទៅ?

ភាព ៖ ក្បាលឡានយើងព្រំដែន ដល់ចឹងយើងរត់ទៅជំរំ ។

ដានី ៖ ក្បាលឡានខាងសំឡូត?

ភាព ៖ បាទ! ភ្នំក្បាលឡាន ។

ដានី ៖ ក្បាលឡាននៅសំឡូត?

ភាព ៖ បាទ! ហ្នឹងហើយ ខ្ញុំរត់ទៅនៅជំរំគេហៅជំរំសាយខេ ។

ដានី ៖ ជំរំសាយខេ?

ភាព ៖ បាទ! បែកគ្នាចេញពីសាយខេ ខ្ញុំទៅសំឡូត ។

ដានី ៖ ពូទៅសំឡូតឆ្នាំណា?

ភាព ៖ ៨៩ ។

ដានី ៖ ៨៩ ទៅសំឡូត?

ភាព ៖ បាទ!

ដានី ៖ ពូនៅសំឡូតបានរយៈពេលប៉ុន្មានដែរចឹង?

ភាព ៖ ឈប់ៗរាប់មើលសិនៗ ៩០ ៩១ ៩២ ៩៣ ៩៦ បានខ្ញុំមក ។

ដានី ៖ ចឹងនៅសំឡូត បានពី៨៩មកដល់៩៦?

ភាព ៖ បាទៗ ។

ដានី ៖ ចុះពូនៅសំឡូតនៅកន្លែងណា?

ភាព ៖ ខ្ញុំនៅអូររថក្រោះ ។

ដានី ៖ នៅអូររថក្រោះនឹង?

ភាព ៖ បាទ! នៅជិតផ្ទះតាជន ។

ដានី ៖ ជិតផ្ទះតាជននឹងម៉ង?

ភាព ៖ បាទ!

ដានី ៖ ស្គាល់អាលី អាឡាដែរ?

ភាព ៖ ជីមិនស្គាល់ ។

ដានី ៖ ខ្ញុំខស្សាហ៍ទៅសំឡូត ខ្ញុំស្គាល់គាត់នឹង ។

ភាព ៖ គេមានប្ដីមានអីអស់ តែឮថាតាជនគេលែងគ្នាហើយ ។

ដានី ៖ បាទ!

ភាព ៖ លែងគ្នាមែន?

ដានី ៖ បាទ! មែនតើ ឥឡូវគាត់ទៅនៅបាត់ដំបង ធ្វើប៉េអ៊ឹមនៅបាត់ដំបង ។

ភាព ៖ ចរិតវាខុសគ្នា ។ បើគាដន គេដាក់ខ្លួន ។ យើងអត់ចេះចូលស្រុក អត់ធ្វើសាមញ្ញក៏ចេះ ដល់ចឹងវាអត់ត្រូវគ្នា ។ វាពិបាក មនុស្សវាធ្វើខុស ខាងលើឲ្យធ្វើចេះ ក្នុងម៉ាខែវាបាន៨លានបាត១នឹង គឺគាត់យកតែ២លានទេ ហើយសល់ប៉ុន្មានដោះស្រាយ ។ តែលុយធម្មតានៅលើអ្នកណា លើនោះហើយ ដោះស្រាយដែលគេឲ្យយើង អត់ ។ វាពិបាកចឹងអាអ្នកខូច គិតតែចូលហោប៉ៅតែខ្លួនឯង រឿងខាងក្រោមអត់ ។

ដានី ៖ ពូស្គាល់តាទិតដែរ?

ភាព ៖ តាទិតនឹង សុទ្ធតែអ្នកដេកលើលុយ ។ លុយមានអ្នកណា មានតាទិត តាម៉េត អ្នកកាន់លុយ ។

ប្រពន្ធ ៖ តាទិននឹងឯង ប្អូនធម៌ខ្ញុំនឹង វារាប់លុយម្តងមានម៉ាឡាន ដឹកដាក់បាវវានៅ៣០បាវ ហើយរាប់ក្នុងបន្ទប់មួយ ហើយប្អូនខ្ញុំវារាប់សឹងថា យកប៉ុន្មានក៏បាន យក១០០ម៉ឺនក៏បាន ។

ដានី ៖ តាទិត គាត់អ្នកគ្រប់គ្រងនៅបវឡាន?

ភាព ៖ បាទ! រឿងតាទិត គាត់អ្នកគ្រប់គ្រង អ្នកដេកលើលុយ ។

ដានី ៖ កាលមុនស្គាល់តាទិត?

ភាព ៖ អត់ទេ ។

ដានី ៖ កាលពីខ្មែរក្រហម?

ភាព ៖ បាទ! អត់ទេ ។

ដានី ៖ ទើបស្គាល់?

ភាព ៖ ទើបស្គាល់គាត់ តាំងនៅសំឡូត ។

ដានី ៖ កាលនៅសំឡូត?

ភាព ៖ បាទ! ប៉ុនគាត់អត់នៅសំឡូតទេ គាត់នៅសែនជៅ ។

ដានី ៖ គាត់នៅណា?

ភាព ៖ គាត់នៅសែនជៅ ។

ប្រពន្ធ ៖ នៅសែនជៅ គេហៅនៅបវឡាននឹងដែរ តែគេហៅ នៅសែនជៅ ។

ភាព ៖ នៅឆ្ងាយគ្នា នៅកន្លែងត្បូង ។

ប្រពន្ធ ៖ នៅកន្លែងត្បូងខ្ញាញ់ នៅតំបន់ត្បូងច្រើន ។

ភាព ៖ តាទិត គាត់នៅសែនថោ ព្រោះថៃឡើងមក ឡើងតាមច្រកនោះ ឡើងមកធ្វើត្បូងធ្វើ គឺត្រូវតែបង់ពន្ធ។ អាដែលយកគ្រឿងចក្រ មកធ្វើត្បូងក៏បង់ឲ្យគេ។

ដានី ៖ ចុះពូធ្លាប់ឃើញមុខគាត់ដែរ?

ភាព ៖ ខានឃើញយូរហើយ។

ដានី ៖ បាទ?

ភាព ៖ បែកគ្នាយូរ។

ដានី ៖ បែកគ្នាយូរ ប៉ុន្តែកាលនៅសំឡូត ឧស្សាហ៍ឃើញគាត់?

ភាព ៖ ឧស្សាហ៍ឃើញ តែឥឡូវបើឃើញក៏មិនចំណាំ គាត់ចាស់។

ដានី ៖ ប្រពន្ធគាត់ឈ្មោះអី?

ភាព ៖ អត់ដែលស្គាល់ទេ។

ដានី ៖ ចឹងម៉េចបានពូ ពី៩៦ ពូផ្លាស់មកនៅ?

ភាព ៖ កន្លែងនេះ គេជ្រើសរើសយកមក។

ដានី ៖ គេជ្រើសរើសយកមក?

ភាព ៖ បាទ! គឺមកដោយស្ម័គ្រចិត្ត គេរើសយកតែអ្នកក្រ ព្រោះកន្លែងនេះមនុស្សវាតិច ហើយច្រកទឹកដីវាធំ ដូច្នេះត្រូវរើសពីខាងសំឡូត១០០គ្រួសារមកដាក់នៅនេះ។

ដានី ៖ ហើយចឹងគេជ្រើសរើសនឹង ពូស្ម័គ្រចិត្តមក ក៏ត្រូវគេតំរូវឲ្យយើងមក?

ភាព ៖ បាទ! គេជ្រើសរើសយើងយកមក បើមកៗស្រេចតែយើង ប៉ុន្តខ្ញុំថាគេឲ្យមកចេះមក។ ថាមិនមកពាដង ហើយគេថាអត់មានឆ្នប អត់មានពេទ្យ ដល់ហើយចឹងមកៗ ខ្ញុំ។ តាកងពលគឺតាពៅនឹង អ្នកយកខ្ញុំមក។ ប៉ុននៅនោះខ្ជិល នៅក៏មិនត្រូវជាមួយពួកខូច។

ដានី ៖ នៅខាងសំឡូតនឹង?

ភាព ៖ អឺ! ទីងតាំងពីគេវៃលោកចោល។

ដានី ៖ គេវៃអីគេ?

ភាព ៖ វៃលោកចោល។

ប្រពន្ធ ៖ មេៗគេវៃលោចោល។

ដានី ៖ ម៉េចចឹងបានគេ ហេតុអីមើលពូមានប្រសាសន៍ចេះ?

ភាព ៖ ហេតុបើតាមខ្ញុំដឹងចេះ ឯកសារនឹង...កាលយើងចេញពីជំរំពីសាយខេមក គេដឹកទៅស្រុកទៅភូមិ។ តាឡី គាត់ទោបង្រៀនចេះ អ្នកបងប្អូនណា ដែលមកពីស្រុកណាឲ្យទៅស្រុកនោះវិញ

ទៅ ព្រោះកាលនោះយើងមិនទាន់ត្រូវគ្នាប៉ុន្មានទេ ។ អាក្រោយមកលោកបួសឯណា ឲ្យទៅវិញ ។ ប៉ុនពួកនោះវៃលោកចោល វៃយកត្បូង ។

ដានី : វៃយកត្បូង?

ភាព : បាទ! លោកមានត្បូង ។

ប្រពន្ធ : ត្បូងលោកៗទៅសុំយាយយ៉ាតៗឲ្យ លោកស្មោះត្រង់លោកប្រតិបត្តិស្មោះត្រង់ ធម៌ព្រះពុទ្ធស្មោះត្រង់ ហើយដល់ចឹងលោកទៅប៉ៃលិន ។ ដល់លោកទៅប៉ៃលិន អាគ្នាអត់ស្គាល់ត្បូងទេ ត្បូងម៉េចវិញលោកយាយ លោកនឹងដុតធូកហើយសុំចង់ស្គាល់មើលឃើញត្បូង ។ ដល់ចឹងលោក យាយយ៉ាតនឹង គាត់អ្នកត្រង់ ហើយចឹងឲ្យត្បូងខៀវៗ លោកក៏អត់ស្គាល់ដែរ ។ ហើយដល់ឲ្យត្បូងខៀវអត់ស្គាល់ទៀត ដល់ចឹងថាយើងឲ្យឯងហើយតើ ម៉េចក៏មិនយក ។

ដានី : អូ! យល់សប្តិ?

ភាព : បាទ! យល់សប្តិ ។

ប្រពន្ធ : យល់សប្តិ ហើយគាត់សុំ លោកចង់ឃើញត្បូង ។

ដានី : លោកយាយយ៉ាត?

ប្រពន្ធ : លោកយាយយ៉ាតប៉ៃលិននឹង ។ ដល់ចឹងឲ្យក្រហមៗប៉ុនមេដៃ ។

ភាព : លោកៗត្រង់ៗ អ្នកដែលស្គាល់លោកអីគឺបង្ហាញ ។

ប្រពន្ធ : លោកត្រង់ ដូចថាប្អូនឯង ខ្ញុំអីចឹង អ្នកដែលស្គាល់លោក គឺបង្ហាញឲ្យ គេមើលទាំងអស់ ។ ដល់ចេះគេអ្នកចង់បាន យកលោកវៃចោលដើម្បីចង់យកត្បូងនឹង ។

ដានី : លោកមកសំឡូតដែរ?

ភាព : បាទ! លោកនៅសាយខេ ដល់ពេលគេដឹកប្រជាជនយើងចេញពីសាយខេ ធ្វើមាតុភូមិនិវត្តន៍ទៅ លោកក៏មកអូររជក្រោះៗនឹងទៅ ។

ដានី : លោកឈ្មោះអី?

ភាព : ឈ្មោះ និល ។

ដានី : តែម៉ាអន្តទេ?

ភាព : ហ្នឹងហើយ លោកនិល ម៉ាអន្ត លោកដូចនៅខាងព្រៃវែង ។

ដានី : ដល់ពេលចឹងឆ្នាំណា?

ភាព : ទេ! អារឿងគេវៃលោកចោលមិនដឹងឆ្នាំ៩០ប៉ុន្មាន ៩៣ ៩៤ ។

ប្រពន្ធ : កំណើតអាសាញ់ គេវៃចោល៩៣ ។

ភាព : ៩៣ ។

ដានី ៖ ពីណាគេអ្នកដូចថាយើង?

ភាព ៖ អូ! អារឿងអ្នកវៃ ពិបាកណាស់ៗ វាគ្មានប្រជារាស្ត្រយើង ទៅណាធ្វើកើត អាណិតលោកៗ លោកលើកទី១ ដឹងដល់មេៗ ត្រឹមកងពលអីគេយាត់ ២-៣សារៗ ប៉ុនលោកថាសុខចិត្តស្លាប់នឹងចុះៗ លោកផ្សេងៗ សឹកអស់ហើយ នៅតែម៉ាអង្គនឹងៗ

ដានី ៖ គេប្រាប់ឲ្យលោកសឹក?

ភាព ៖ យើងគ្នាយើង អាណិតលោក ព្រោះគេរករឿងលោក គេតាមដានលោកច្រើនៗ

ដានី ៖ ម៉េចបានគេតាមដានលោក?

ភាព ៖ ដូចខ្ញុំថាអារឿងៗ

ដានី ៖ គេអត់សូវចូលចិត្តលោក?

ភាព ៖ អឺ! វាពិបាក ប្រជាជនចូលចិត្តៗ

ប្រពន្ធ ៖ ប្រជាជនចូលចិត្ត ប៉ុនមេៗ អត់ចូលចិត្តៗ

ដានី ៖ មេៗណា មេអ្នក?

ភាព ៖ មេពួកតាបុត ពួកអី ពួកអាណាងទៅពីនេះៗ

ប្រពន្ធ ៖ តាណាង ហើយណាទៀត អាមួយកំបុតជើងនេះអ្នកវៃផ្ទាល់ម៉ង ឈ្មោះអាអីៗ

ភាព ៖ ឈ្មោះអាស៊ីនឹង វាងាប់បាត់ៗ

ប្រពន្ធ ៖ វាងាប់ទៀត វៃលោកភ័យ ឲ្យគេស្រោចទឹក ប៉ុនឥឡូវងាប់ហើយ លោកយកទៅវិញៗ

ដានី ៖ តាម៉េតអីនឹង?

ភាព ៖ តាម៉េតអត់ទេៗ

ដានី ៖ តែមេតាម៉េត?

ភាព ៖ អឺ! វាត្រូវរូបគ្នាហើយៗ

ដានី ៖ ក្រុមត្រូវគ្នា?

ភាព ៖ ក្រុមគ្នាគេ ហើយម្យ៉ាងលុយអត់បានទៅលើឪពុកក្មេកគេអ្នកកាន់ៗ

ប្រពន្ធ ៖ អើយ! តាបុតនឹង គាត់គេអ្នកកាន់កាប់ដែរ គេមេ គេប្រធានពេទ្យៗ

ភាព ៖ គេតំរូវ តាមដានលោក ខ្ញុំនៅនឹងឃើញទាំងអស់ៗ

ប្រពន្ធ ៖ តាមដានលោក ដែលឪនឹងធ្វើតាអាចារ្យ ដល់ពេលលុយនឹងៗ

ភាព ៖ លុយប្រជាជនអត់ឲ្យតាអាចារ្យកាន់ៗ

ប្រពន្ធ ៈ អត់ឲ្យអាចារ្យនឹងកាន់ អាចារ្យនឹងវាអាក្រក់ ដល់ចឹងទុកនៅលើលោកចុះ ទុកកសាង ហើយធ្វើបុណ្យ ប្អូនឯងគិតមើលម៉ាភ្នំវានឹង មើលសរុបម៉ាថ្ងៃចប់ម៉ង វាបានដូចថា១០ម៉ឺន បាត ១០លានចឹងណា ទុកកសាងវត្ត។

ដានី ៈ ចឹងកាលនឹងវត្តនៅអូររថក្រោះមានណា?

ភាព ៈ កាលនឹងអត់ទាន់មានទេ ទិញផ្ទះគេ។

ប្រពន្ធ ៈ ទិញផ្ទះគេម៉ាម៉ឺនបាត។

ភាព ៈ ផ្ទះនឹងគេធ្វើមន្ទីរសន្តិសុខ។

ដានី ៈ បាទ! ឥឡូវវត្តគេនៅណា?

ភាព ៈ ឥឡូវវត្តគេនៅស៊ុង វត្តថ្មីគេ។

ប្រពន្ធ ៈ ឥឡូវវត្តគេនៅស៊ុង នៅរាល់ថ្ងៃនឹង។

ដានី ៈ វត្តនៅស៊ុង កន្លែងផ្ទះតាមុត?

ភាព ៈ អត់ទេ។

ដានី ៈ តាមុតនៅកន្លែង?

ភាព ៈ តាមុតនៅនេះ ទៅពីអូរផ្លូវរទេះឆ្ងាយទៀត។

ដានី ៈ តាមុត នៅអន្លង់ពួក?

ភាព ៈ អូ! តាមុតយើងនៅនេះ នៅអូរអង្រែ។

ប្រពន្ធ ៈ ប៉ុន្តែវត្តនឹង វត្តអូររថក្រោះរាល់ថ្ងៃនឹង វានៅកន្លែងម្តុំស៊ុង។

ដានី ៈ មិនមែនវត្តពីមុន?

ប្រពន្ធ ៈ ហើយប៉ុនឥឡូវគេថាដូចមានវត្តភូមិកណ្តាលមួយទៀត។

ភាព ៈ ហ្អឹងហើយ វត្តភូមិកណ្តាល គេនៅកន្លែងវត្តចាស់។

ប្រពន្ធ ៈ ឥឡូវនេះ គេធ្វើបុណ្យមាឃបូជាថ្ងៃមុននេះ លោក១២០អង្គ ខ្ញុំស្តាប់វ៉ាដ្យូនៅវត្តអូររថក្រោះ គេផ្សាយ គេទេសនានឹង។

ដានី ៈ ចឹងពេលគេសម្លាប់លោកចឹងទៅ អត់មានបញ្ហា គេអត់មានរករឿងអី?

ប្រពន្ធ ៈ យើងគេអ្នកមេៗ ហើយយើងនៅក្រោមគេ យើងធ្វើគេអត់ឈ្នះ។

ភាព ៈ យើងទៅហ៊ានរករឿងគេ។

ដានី ៈ តែលោកម៉ាអង្គទេ?

ភាព ៈ បាទ!

ដានី ៈ គេយកហេតុផលអី?

ភាព ៖ ហេតុផល ថាលោកក្បត់ លោកជួយកញ្ញា លោកមានកន្ទុយក្អែក ។ ធម្មតាប្រជាជនបាន ក្អែកកន្ទុយយកប្រគេនលោកហើយ ។ គេចេះតែ ចោទ ។

ដានី ៖ ថាលោកក្បត់ លោកជួញកញ្ញា?

ភាព ៖ គេចេះតែថា ។

ប្រពន្ធ ៖ ជួញកញ្ញា។ តែម្តុំប៉ុននេះលោកសុំប្រជាជនមក មកប្រគេនថា យកមកស្ងួត លោកឆាន់ព្រះ កេះ ប៉ុនគេចេះចោទ ។

ភាព ៖ វាគ្មានអីភស្តុតាងសំខាន់ ធម្មតាលោកបួស លោកវាមានផែយា ដល់ចិនគេថាលោកមានឯក សារ គ្មានស្អី បើអត់អានឹងមិនថាលោក ។ អានឹងហើយគេថា ដុតឲ្យខ្លោច រោយឲ្យឆៅ ។ យើងប្រជាជន ។

ដានី ៖ ចិនដល់ឆ្នាំ៩៦ យើងនេះមក?

ភាព ៖ បាទ! ៩៦គេរើសមក។ខ្ញុំមកនេះបណ្តោយ ។ មនុស្សណាដែលធ្វើខុសនឹងច្បាប់។ គេដឹកនាំ ឲ្យមនុស្សល្អ ដល់ឯងទៅធ្វើចិន ។ ហើយដល់សម្លាប់លោក អាណាអ្នកថាខ្មែរក្រហម។ មាន អ្នកសម្លាប់ណា បុគ្គល វាចេះតែចិន ។ បានថាពួកអានេះ ចិនតើ បានជិនាន់២-៣ឆ្នាំ ផាប់ គេឲ្យបាយប្រជាជន ព្នម៉ាថ្ងៃ៣ពេល ហូបឲ្យឆ្អែត បើហូបមិនឆ្អែត គេត្រូវស្នើទៅខាងពួក នេះ ពិបាកណាស់ ។

ដានី ៖ អ្នកដឹកនាំដូចពូមានប្រសាសន៍មិញ?

ភាព ៖ អ្នកដឹកនាំវាចិន ។

ដានី ៖ អ្នកកាន់ត្បូង កាន់លុយអីចិន ដល់ពេលចិន យកលុយយកអី?

ភាព ៖ បាទ! នឹង ហើយយើងមិនស្មោះត្រង់ ។

ប្រពន្ធ ៖ លុយវា១០លាន ១៥លានហើយ ហើយលោកអត់ចេះលាក់ទេ ដូចថាឥឡូវបងខុះលុយ បងយកលុយទៅចាយសិនទៅ ធ្វើផ្ទះសិន ទម្រាំអាត្មាទិញនេះទិញនោះបានធ្វើកុដិធ្វើអីចិនចាំ យកមកឲ្យអាត្មាវិញ ។ លោកចិត្តល្អចឹង ថាប្រជាជនដូចថាផអ្នកក្រចឹង ញោម បងអីយក អង្ករ ទៅហូបខ្លះទៅ អ្នកអត់ ។ គេអ្នកមានគេយកមកឲ្យប្រគេន អាត្មាឲ្យ ។ ហើយដល់ចិន គេអ្នកមាន គេចង់បានលុយនឹងច្រើនណាស់ គេចង់បានត្បូងនឹង ។ ដែលគ្រាន់គេចាប់លោក ចិន យប់ឡើងខ្ញុំយល់សប្តិ។ឃើញលោកមក អង្គុយធ្វើចេះ មកដល់ប្រាប់។គេដោះអស់ រលីង មកដល់ធ្វើដៃចេះ បែរខ្នងឲ្យខ្ញុំ ។ ខ្ញុំថា *«លោកបងមកពីអន្លង់? អត់ឲ្យករុណាអត់ដឹង អីតិច»* *«បងអើយ! អ្នកវៃចោលអាត្មាតែ២នាក់ទេ»* មកដល់ប្រាប់ចិនបណ្តោយ ។ ហើយខ្ញុំ

ភ្ញាក់ពើល ព្រឹកឡើងទៅបណ្តោយ ខ្ញុំនៅចំការនោះ ។ ដល់ទៅ គេថាចាប់លោកបងបាត់ហើយ ។

ភាព ៖ មកនេះក្នុងម៉ាគ្រួសារ គេគិតផ្ទះម៉ាខ្នង គោម៉ានឹម ប្រាក់៥០០០ពាន់ សម្រាប់ម៉ាផ្ទះ គឺខាងលើគេផ្តល់ឲ្យ ។

ប្រពន្ធ ៖ តាមការពិតខាងក្រោមអត់បានអី ។

ភាព ៖ អូ! យើងមិនដែលបានអី ។

ដានី ៖ គេអត់ឲ្យ?

ភាព ៖ បាទ! ហើយមើលលុយ ដែលគាត់យកមកឲ្យ នៅលើអាកញ្ចាស់ ស៊ឹម គ្មានឲ្យម៉ារៀល ។

ដានី ៖ នៅលើអ្នកណាគេ?

ប្រពន្ធ ៖ នៅលើតាស៊ឹម ប៉ុនឥឡូវបាត់ហើយ តាមស៊ឹម ។

ភាព ៖ អាកញ្ចាស់ ស៊ឹម ។

ដានី ៖ ស៊ឹម នឹងគាត់ធ្វើអី?

ភាព ៖ ទេ! គេអ្នកធំ ។

ដានី ៖ អ្នកគ្រប់គ្រងខាងយើងនឹង?

ភាព ៖ ហ្នឹងគ្រប់គ្រង មិនមែនគ្រប់គ្រង ។

ប្រពន្ធ ៖ ដឹងគេខាងអីផងតាស៊ឹម នឹង កាលនឹងតាៗ ពួកខ្ញុំនេះ គាត់ដឹងថា យើងពីមុនមកដែលយើងនៅកន្លែងកងការពារតាៗនឹង ដល់ចឹងគាត់មកសួរកថា ពួកខ្ញុំនៅកន្លែងណា ។ ថាកុំទៅកន្លែងនឹងខ្លាំងនៅទេ ។

ភាព ៖ គេថាពួកអានេះចូលឃួនហើយ ការពិតគ្មានស្អី ។

ប្រពន្ធ ៖ ដល់ហើយថាបើខ្លាំងឯងចឹង ទុកលុយនៅលើស៊ឹមឯង មាសប៉ុន្មានកេះ ហើយលុយៗប៉ុន្មានជិត១០សាក់កាដូ ដឹងប៉ុន្មាន ។

ភាព ៖ ចូលម្នាក់ម៉ាគ្រួសារ២៥០០បាត ។

ដានី ៖ តាណា?

ភាព ៖ មកជាមួយតានួន តាម៉ុក ហើយតាសុន សេន ។

ដានី ៖ តានួន ជា, តាម៉ុក?

ភាព ៖ ហ្នឹងហើយមុននឹងយើងមកនេះនឹង ៩៦ ហើយគាត់មកនេះ ខែប៉ុន្មានវស្សាឆ្នាំ៩៦ ។

ដានី ៖ ពួមកយើងមករស់នៅនេះតាំងពីឆ្នាំ៩៦?

ភាព ៖ បាទ! ៩៦ ។

ដានី ៖ នៅភូមិផ្ទះខាងនេះបណ្តោយ?

ភាព ៖ នៅខាងនោះស៊ីង ។

ដានី ៖ នៅខាងនោះស៊ីង ទើបមកនៅនេះ?

ភាព ៖ ទើបមកនៅនេះ យើងឡើងទៅជំរំ ។

ប្រពន្ធ ៖ ទៅជំរំៗ ថ្ងៃប៉ុន្មាន យើងរៃគ្នាម៉ាសារ ។

ដានី ៖ ៩៧?

ភាព ៖ យើងរដ្ឋប្រហារ ឈើផងមិនដឹង ។

ប្រពន្ធ ៖ ទៅជំរំម៉ាសារចឹងហើយ បានមកនេះ បានចាប់ផ្តើមនៅតាមថ្នល់នេះធ្វើ ។ ថ្នល់នេះធ្វើមុន ដំបូងធ្វើនឹងកាំបិទ និងពូថៅ ចបទេ កូនខ្ញុំធ្វើ តំរង់ហើយ ខ្ញុំរើសមីនដាក់ម៉ុំៗ ។

ដានី ៖ កាលនឹងមានមីនមានអី?

ប្រពន្ធ ៖ អួយ! មីនច្រើនណាស់ប្អូន នេះផ្លូវ៥៦ នៅខាងនោះតិច ។

ភាព ៖ ផ្លូវ៥៦ ផ្លូវមីន ។

ប្រពន្ធ ៖ ហើយឡានផាប់ និយាយពីឡានច្រើនណាស់ ឲ្យតែឡាននៅម៉ុំស្ពានៗ សុទ្ធតែឡាន សុទ្ធតែខ្មោចឡាន ខ្ញុំមកមុនដំបូងសុទ្ធតែខ្មោចឡានៗច្រើនណាស់ សុទ្ធតែមីន រើសគរៗម៉ុំៗ ។

ដានី ៖ ចុះពូតាំងពីសមាហរណកម្មអីមក ទៅលេងផ្ទះបានម្តង?

ភាព ៖ បាទៗ ទើបទៅលេងបានម្តង ។

ដានី ៖ ឆ្នាំណា ដែលពូទៅលេងផ្ទះ?

ភាព ៖ ២០០៦ ។

ដានី ៖ ពូម៉េចដែរ ដូចបែកផ្ទះយូរតាំងពីឆ្នាំ៧០ជាង?

ភាព ៖ អឺ! ទៅហួសផ្ទះ ។

ប្រពន្ធ ៖ អឺ! ទៅឡើងវង្វេងផ្ទះ ។

ដានី ៖ ទៅវង្វេងផ្ទះ ចុះបងប្អូននៅប៉ុន្មាននាក់?

ភាព ៖ បងប្អូនខ្ញុំនៅៗ២នាក់ នៅប្អូនមួយ បងមួយ ។

ដានី ៖ ទៅស្គាល់គ្នា ដល់តែ២នាក់?

ភាព ៖ អត់អីទេ ទៅម្តាយមីងខ្ញុំជូន ប្រាប់ប្រវត្តិ ។ គេអត់ជឿ ។

ប្រពន្ធ ៖ គេអត់ជឿ គាត់ពីមុនមាឌធំនោះ ដល់ពេលត្រូវរបួស វានៅតូច ដល់ហើយចឹងគេថាម៉េចក៏តូច ហើយចឹងគាត់ថាចឹង ។ ដល់ពេលគាត់និយាយប្រវត្តិ អារឿងដីធ្លីស្អីៗ ប្រាប់ដំណើរដំណាងបានគេជឿថា នឹងមែនហើយចឹង ។

ភាព ៖ ៣៨ឆ្នាំ ។

ដានី ៖ ៣៨ឆ្នាំ កាលពូនៅក្មេង ពូមាឪធំ?

ភាព ៖ បាទ! អឺ! ជនជាតិសែនខ្ញុំ៤នាក់ កាលខ្ញុំត្រូវរបួសនេះ របួសនៅរតនគីរី ។

ដានី ៖ ដែលប្អូនៗដែលពូទៅ អត់ស្គាល់ទេ?

ភាព ៖ អត់ ។

ដានី ៖ ដូចនៅក្មេងៗ ?

ភាព ៖ បាទ! គេស្គាល់តែពីក្មេង ដល់យើងមក មានដល់ចៅហើយបានទៅ គេគ្មានស្គាល់ណា គ្មានអ្នកណាស្គាល់ ។

ដានី ៖ ពូទៅបានប៉ុន្មានថ្ងៃដែរ?

ភាព ៖ ទៅជាងកន្លះខែ វាអត់ចង់ឲ្យមកទេ ។

ប្រពន្ធ ៖ ប៉ុននឹកឃើញកូននៅនេះ ។

ដានី ៖ ម៉េចបានគាត់អត់ចង់ឲ្យមក ដោយសារនឹក?

ភាព ៖ បែកយូរ វាថានៅឲ្យបានច្រើនថ្ងៃ ។

ដានី ៖ ប៉ុន្តែ គាត់ដែលមកលេងពូទេ?

ភាព ៖ អត់ទេ មកបងមកលេង កាលពី...។ មកកាលឆ្នាំ៩០ ។

ដានី ៖ បងពូ កាលពេលពូទៅវិញ?

ភាព ៖ ទៅជួបគាត់ៗមកលេងខ្ញុំ ។

ដានី ៖ តែស្គាល់គ្នាដែរ?

ភាព ៖ ស្គាល់ ។

ដានី ៖ ប្អូនអត់ស្គាល់?

ភាព ៖ អត់តែប្អូន ។

ដានី ៖ ចឹងពូមានគំរោងទៅលេងផ្ទះទៀតដែរអត់?

ភាព ៖ ហឺ! មានចេះចង់ទៅ ប៉ុនវាយ៉ាប់អារឿងលុយ ចង់ទៅភ្ជុំ ។

ដានី ៖ ចង់ទៅពេលភ្ជុំ?

ភាព ៖ វាឆ្នាំនេះ យើអ៊ុនដាក់ ចុះគ្រាន់តែ....។

ប្រពន្ធ ៖ គាត់នៅក្រោមផ្ទះនឹង ថ្ងៃមុន ខែមុន ជ្រូកខ្លួនឯង ជ្រូកកូនជ្រូកបានឹង វាហក់មកបុក វាខ្ទេះប្រវែងនេះប្អូនអើយ ហើយលូកម៉ាលេចមកនេះ ព្យាបាលគ្រាន់តែបង់ឲ្យពេទ្យគេអស់១លានជាង ។

ភាព :	ឥឡូវហូបបាយ រាល់ថ្ងៃនឹងមិនដេកទេ អន្ទុយ ។

ដានី :	ជ្រូកយើងជ្រូកស្រុកនឹង?

ប្រពន្ធ :	ជ្រូកបារបស់កូនខ្ញុំនឹង វារួចពីទ្រុងមក វាងងឹតៗហើយ បែបវាស្រវាំងភ្នែកវា ។

ភាព :	អត់ទេ ជ្រូកនោះតាំងពីយកទៅ ពួកនោះវ៉ៃ ដល់ចឹងវាចឹង ។

ប្រពន្ធ :	ហ្នឹងហើយយកទៅតាឆុយវ៉ៃ ជ្រូកបាគេអត់ឲ្យវ៉ៃទេ ។ ដល់កូនខ្ញុំនឹង យកទៅដាក់មេគេៗវ៉ៃហើយ បើសិនជាម្ចាស់ជ្រូកមេគេ គាត់ឡើងលើគ្រែគាត់ហើយ វាស៊ុះទៅអាក្រញ៉ាំខ្សែនោះ វាដាប់នៅចេះ វាទៅអត់រួច បើសិនជាមិនដាប់ខ្សែគេនឹង ទៅខ្ទេះគេបង់ឲ្យគេមិនស្មើរទេ បង់ឲ្យគេមិនស្មើរទេ កូនគេ ប្ដីគេ ប៉ុនគាត់អង្គុយលើគ្រែ វាហក់ទៅលើទៀត ។

ភាព :	យើងកុំទៅធ្វើបាបវា ហើយខ្ញុំមិនដែលធ្វើអីទេ ។

ដានី :	ចុះពូមកដល់សព្វថ្ងៃ ពូមានដែលឮពត៌មានទាក់ទងពីការកាត់ទោស?

ភាព :	ឮ ស្ដាប់វិទ្យុ ឮតែគេថា ។

ដានី :	ឮតែគេថា?

ភាព :	បាទ!

ដានី :	ពីអត់ដែលបានមើលទូរទស្សន៍អីអត់?

ភាព :	អត់ទេ អត់ ។ មានទូរទស្សន៍ អត់មាន ឮតែគេថា ។

ដានី :	ពូយល់ថាម៉េចដែរ ពេលគេកាត់ទោសកាត់អីនឹង?

ភាព :	ធម្មតា គេធ្វើឲ្យអស់ចិត្តប្រជាជន ។

ដានី :	គេធ្វើឲ្យអស់ចិត្តប្រជាជន?

ភាព :	កាត់ៗទៅ ។

ដានី :	ពូដូចថាពូធ្លាប់រស់នៅជាមួយតាៗអី គាត់អីដូចថា?

ភាព :	យើងបើអត់ពីគាត់ ក៏វាអត់មានមកដល់សព្វថ្ងៃ ។ អត់ពីគាត់រលាយអស់ហើយ កុំទៅចង់សាក់ ។ យើងថាគាត់ក្បត់ជាតិ ជំនាន់គាត់ អត់មានអស់ដីម៉ាចំអាមទេ ហើយអារឿងស្លាប់ ២-៣ឆ្នាំ ក៏មិនមែនគាត់អ្នកសម្លាប់ គឺវាមានអាពួកស្រឡាញ់គាត់ មានអ្នកស្អប់គាត់ គំរោងគាត់តាមដែលខ្ញុំត្រូវរៀន គេត្រូវចាយលុយ ។

ដានី :	ត្រូវចាយលុយ?

ភាព :	បាទ! ធម្មតាគេដឹង គេអ្នកធ្វើ ប៉ុនទំនាយវាត្រូវចឹង ព្រោះយួនគឺមហិចតាឈ្លានពាន មិនមែនយួនមកជួយខ្មែរ គឺច្បាស់លាស់ ។

*ដានី ៖* *បាទ! ពូខ្ញុំគ្មានអី ដូចអស់សំនួរត្រូវសួរនាំពូទៀតហើយ ចឹងពូមានអីចង់បន្ថែមនូវអ្វី ដែលខ្ញុំអត់បានសួរ?*

*ភាព ៖* *គ្មានអីបន្ថែមទេ ប៉ុនគ្រាន់ថាអើ!រឿងគេកាត់ទោសកាត់ទៅ ព្រោះអីអ្នកចង់ដឹងថាអ្នកណាខុសអ្នកណាត្រូវ ទៅកាត់ហើយ.....កាត់ឲ្យឆាប់ទៅ ខ្លាចគាត់ចាស់ៗហើយ មិនដឹងថាម៉េចៗគ្រាន់ថាអើ!ចាំតែមើល យើងជាមនុស្សស្លាប់ហើយ គ្មានថ្ងៃ១៨រដ្ឋប្រហារក៏គ្មានស្រុកនេះយើងទៅឆ្ងល់អី នៅលើដី អត់ដីទៅនៅណា ។*

*ដានី ៖* *បាទៗ ចឹងខ្ញុំអរគុណពូច្រើន ដែលចំណាយពេលផ្តល់សម្ភាសន៍ជាមួយពួកខ្ញុំ ទាក់ទងនឹងជីវិតរបស់ពូ តាំងពីក្មេងរហូតដល់បច្ចុប្បន្ននេះ ។ បាទ! ខ្ញុំអរគុណច្រើន ។*

*«ចប់»*